AFESIP

AGIR POUR LES FEMMES EN SITUATION PRÉCAIRE

# របាយការណ៍ប្រចាំឆ្នាំ២០២១

## ស្តីអំពី

# ការប្រតិបត្តិសកម្មភាពការងារ
# អង្គការអេ ហ្វេស៊ីប-កម្ពុជា

## ខែមករា ដល់ ធ្នូ ឆ្នាំ២០២១

អ្នកធ្វើរបាយការណ៍: **លោក សៅ ឈឿត**
**នាយកកម្មវិធី**
E-mail: afesip.nc@gmail.com

## I.ការពិពណ៌នាអំពីអង្គការ

អង្គការ អាហ្វេស៊ីប កម្ពុជា បានបង្កើតឡើងនៅឆ្នាំ១៩៩៦ ដោយ **លោកស្រី សុម៉ាលី ម៉ម** (លោកស្រីផ្ទាល់ជាជនរងគ្រោះដោយការជួញដូរ) ក្នុងគោលបំណងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ លើស្រ្តី និងកុមារ។ អង្គការ អាហ្វេស៊ីប កម្ពុជា ប្រយុទ្ធប្រឆាំង នូវគ្រប់ទំរង់ នៃការជួញដូរមនុស្ស និង វិធានការការពារ ក្នុងគោលបំណងកាត់បន្ថយ តម្រូវការជនរងគ្រោះដោយការជួញដូរមនុស្ស តាមរយៈការប្រយុទ្ធប្រឆាំង អំពើហឹង្សាលើស្រ្តី-កុមារី (វិសមភាពយែនឌ័រ) ព្រោះថាអំពើហឹង្សាលើស្រ្តី-កុមារី វាជាផ្នែកមួយនៃបញ្ហាសិទ្ធិមនុស្ស។

អង្គការ អាហ្វេស៊ីប កម្ពុជា ធ្វើការជួយដល់យុវនារី និងកុមាររងគ្រោះ ឬមានហានិភ័យខ្ពស់ក្នុងការងាយរងគ្រោះដោយអំពើជួញដូរផ្លូវភេទ ហឹង្សា រំលោភបំពាន រំលោភសេពសន្ថវៈ ទាសភាពជាប់កិច្ចសន្យា ឬកេងប្រវ័ញ្ច ដោយសហការជាមួយគ្រួសាររបស់ពួកគាត់ ក្នុងការផ្តល់សុវត្ថិភាព និង ការផ្តល់យុទ្ធសាស្រ្តអោយចាកចេញដោយនិរន្តភាព។

អង្គការ អាហ្វេស៊ីប កម្ពុជា ធ្វើការយ៉ាងជិតស្និតជាមួយមន្រ្តីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងបណ្តាដៃគូអន្តរជាតិនានា ដើម្បីផ្តល់តំណោះស្រាយសម្របចំពោះបញ្ហាពាក់ព័ន្ធ។

### ១.១ ចក្ខុវិស័យ

ជាពិភពលោកមួយដែលយុវនារី និង កុមារីមានសុវត្ថិភាពរួចផុតពីទាសភាព

### ១.២ ទិសដៅ

អង្គការ អាហ្វេស៊ីប កម្ពុជា ផ្តល់ការថែទាំ និង ធានាបាននូវសិទ្ធិរបស់យុវនារី និង កុមារីរងគ្រោះ និងងាយរងគ្រោះ ដោយអំពើទាសភាព តាមរយៈការស្តារនីតិសម្បទា ការអប់រំ បណ្តុះបណ្តាល និងសមាហរណកម្មដោយជោគជ័យ ត្រឡប់ទៅសង្គមវិញ ដោយឯករាជ្យភាពហិរញ្ញវត្ថុ និរន្តរភាព និង ភាពថ្លៃថ្នូរប្រឌិត។ យើងអនុវត្តការងារនេះដោយជួយជ្រោមជ្រែង និង បង្ហាត់បង្រៀនពួកគាត់ អំពីឯកភាពហិរញ្ញវត្ថុ តាមរយៈនិរន្តភាពមុខរបរ។ បន្ទាប់មកយើងស្វាគមន៍ លើកទឹកចិត្តអោយពួកគាត់ ក្លាយជាផ្នែកមួយរបស់បណ្តាញអតីតៈជនរងគ្រោះ ។

### ១.៣ ក្រុមគោលដៅ

ជាយុវនារី និង កុមារីជនរងគ្រោះ និងងាយរងគ្រោះ ដោយការជួញដូរ រំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទ។

### ១.៤ យុទ្ធសាស្រ្ត

ការប្រយុទ្ធប្រឆាំង អំពើជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទ លើយុវនារី និង កុមារី គឺជាកាតព្វកិច្ចដ៏ធំមួយដែលតម្រូវអោយមានពហុធនជាន។ យើងបានយកចិត្តទុកដាក់យ៉ាងខ្លាំង នូវតម្រូវការរបស់យុវនារី និង កុមារីនីមួយ ៗ ដែលយើងធ្វើការជាមួយ មកពិចារណាយ៉ាងហ្មត់ចត់ ដើម្បីផ្តល់ដំណោះស្រាយសមស្របដល់ពួកគាត់ តាមរយៈកម្មវិធីសំខាន់ ៗ ចំនួន៤ **(១) កម្មវិធីស្តារនីតិសម្បទា** (រួមមាន ការថែទាំសុខភាពកាយ សុខភាពផ្លូវចិត្ត ( ចិត្តសាស្រ្ត ) និងការគាំពារផ្នែកនីតិកម្ម)**(២) កម្មវិធីអប់រំ និងហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ** (រួមមានការអប់រំក្នុងប្រព័ន្ធ ភាសាអង់គ្លេស កុំព្យូទ័រ និងបណ្ណាល័យនៅមណ្ឌល ការអប់រំសហគមន៍ អាហារូបករណ៍សកលវិទ្យាល័យ និងហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ **(៣) កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច** (សមាហរណកម្ម) និង **(៤) កម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ** ក្នុងការផ្លាស់ប្តូ

ជីវិតជនរងគ្រោះ និង ជនងាយរងគ្រោះអោយក្លាយជាអតីតជនរងគ្រោះ និងត្រៀមទទួលយកការកែប្រែជីវិតថ្មី ដោយការទទួលខុសត្រូវ និងស្វ័យតម្លាភាព នូវជំនាញចាំបាច់ ដើម្បីអោយមាននិរន្តភាពសំរាប់ខ្លួនឯង និង គ្រួសារ។

ដើម្បីអោយមានតម្លាភាព ប្រសិទ្ធិភាពដល់យុវនារី និង កុមារីជាអ្នកទទួលផលពីកម្មវិធី ក៏ដូចជា ដើម្បីផ្តល់តម្លាភាព ជូនម្ចាស់ជំនួយ យើងមាននីតិវិធីជាក់លាក់ក្នុងការផ្តល់ជូនវឌ្ឍនភាពគំរោង ដែលអាចវាយតម្លៃពីការវិវឌ្ឍន៍ និងសមទ្ធិផលសំរេចបានរបស់គំរោង ដោយក្រុមការងាររបស់អង្គការ អាហ្វេស៊ីប កម្ពុជា បានដាក់ចេញនូវទិសដៅជាក់លាក់ដែលអាចវាស់វែងបាន អំពីសុច្ចនៈករដែលបានរំពឹងទុក និង ផែនការណ៍សម្មភាពដែលអាចធ្វើបាន និងអាចវាស់វែង អាចបង្ហាញអំពីលទ្ធផលសំរេចបាន នៅចុងកម្មវិធីនៃការអនុវតគំរោងនីមួយៗ។

## II. អន្តរកម្មវិធីគន្លឹះទាំង៤របស់អង្គការ

ខាងក្រោមនេះជាកាពិពណ៌នា អំពីកម្មវិធីទាំងឡាយដែលជាការឆ្លើយតបទៅនិងចក្ខុវិស័យ និង ទិសដៅចំបងៗ ដែលអង្គការ អាហ្វេស៊ីប កម្ពុជា កំពុងប្រតិបត្តិការសកម្មភាពការងាររបស់ខ្លួនដោយអនុលោមតាមយុទ្ធសាស្ត្រដែលមានស្រាប់។

## ២.១ កម្មវិធីស្តារនីតិសម្បទា

កម្មវិធីស្តារនីតិសម្បទានៅទីនេះយើងកំណត់លើទីកន្លែងសុវត្ថិភាពនិងព្យាបាលជាកន្លែងដែលផ្តល់ការស្នាក់នៅដោយសុវត្ថិភាព អាហារមួយថ្ងៃ៣ពេល ការថែទាំ អាហារូបត្ថម្ភផ្សេងៗ ការថែទាំសុខភាព ការពិគ្រោះយោបល់ចិត្តសាស្ត្រសង្គម ជំនួយផ្នែកច្បាប់ ការអប់រំក្នុងប្រព័ន្ធនៅសាលារដ្ឋ ថ្នាក់រៀនភាសាអង់គ្លេស ថ្នាក់រៀនកុំព្យូទ័រ ការចូលអានសៀវភៅផ្សេងៗនៅបណ្ណាល័យក្នុងមណ្ឌល ហ្វឹកហ្វឺនជំនាញបំណិនជីវិតផ្សេងៗ ការហ្វឹកហ្វឺនរាំរបាំប្រពៃណីខ្មែរ ហ្វឹហ្វឺនយោគៈ ហ្វឹកហ្វឺនសមាធិ និងសកម្មភាពកីឡាផ្សេងៗ ក្នុងគោលបំណងអភិវឌ្ឍន៍សុខមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះដែលយើងធ្វើការជាមួយ។

ដំណាក់កាលដំបូងគឺយើងជួយអោយជនរងគ្រោះ ឬ ជនងាយរងគ្រោះមានលំនឹងផ្លូវចិត្ត ពីវិបត្តិដែលពួកគេជួបប្រទះ ជាទូទៅយើងផ្តល់នៅមណ្ឌលស្តារនីតិសម្បទា ទុំឌី ដែលជាកន្លែងអោយពួកគាត់អាចទទួលបានបរិយាកាសសុវត្ថិភាព ជួបជាមួយវេជ្ជបណ្ឌិត (គ្រូពេទ្យ) និងគិលានុប្បដ្ឋាយិកា បុគ្គលិកចិត្តសាស្ត្រ បុគ្គលិកគាំពារច្បាប់ បុគ្គលិកថែទាំ សមាជិកបណ្តាញអតីតជនរងគ្រោះ កសាងទំនុកចិត្តនិងទំនាក់ទំនងជាមួយមនុស្សដែលមានទឹកចិត្តល្អតាមរយៈកម្មវិធីឪពុកម្តាយធម៌ និងទទួលបាននូវតម្រូវការចាំបាច់ផ្សេង ៗទៀត តាមតម្រូវការជាក់ស្តែងរបស់ពួកគាត់។

**របាំប្រពៃណីខ្មែរ យោគៈ និងសមាធិ**-យើងផ្តល់ការហ្វឹកហ្វឺនបណ្តុះបណ្តាលទាំងនេះដល់កុមារី ក្នុងគោលបំណងធ្វើការអភិវឌ្ឍទាំងសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត ដល់កុមារី ក៏ដូជាបណ្តុះបណ្តាលកុមារីអោយស្គាល់ពីរបាំប្រពៃណីខ្មែរ ព្រោះថាវាជាប្រវត្តិសាស្ត្រដ៏យូលុងនៃវប្បធម៌កម្ពុជា។

### ២.១.១ សុខភាព

ការជួញដូរផ្លូវភេទ រំលោភសេពសន្ថវៈ ការរំលោភបំពានផ្លូវភេទ ឬការកេងប្រវ័ញ្ចផ្លូវភេទ បានបណ្តាលអោយមានវិបត្តិមហន្តរាយដល់ការអភិវឌ្ឍន៍ជាសកល ជាពិសេសជនរងគ្រោះដោយអំពើឧក្រិដ្ឋនេះតែងតែដក់ជាប់នូវស្លាក់ស្នាមវិប្បដិសារី និងសុខភាពផ្លូវចិត្តធ្ងន់ធ្ងរជាបច្ច័យធ្វើអោយប៉ះពាល់ដល់ការអភិវឌ្ឍន៍រាងកាយនិងស្មារតី។ ដើម្បីជួយ

ជនរងគ្រោះអោយចេញផុតពីស្លាក់ស្នាមវិប្បដិសារី និងសុខភាពផ្លូវចិត្តធ្ងន់ធ្ងរបាន យើងត្រូវការផ្តល់សេវាកម្មស្តារនីតិសម្បទាដែលមានគុណភាពដល់ពួកគាត់  ក្នុងគោលបំណងជួយអោយអតីតជនរងគ្រោះរស់នៅដោយឯករាជ្យ  ជីវិតមានសុវត្ថិភាព និងភាពរីរាយក្រោយពីការស្តារនីតិសម្បទា និងសមាហរណកម្មទៅតាមសហគមន៍វិញ ។

មណ្ឌលស្តារនីតិសម្បទាទុំឌី  ជាកន្លែងតំណាក់កាលបឋមនៃការចាប់ផ្តើមការព្យាបាលជនរងគ្រោះពីផលប៉ះពាល់រាងកាយ ស្មារតី ជាកន្លែងស្នាក់នៅមានសុវត្ថិភាព ព្យាបាល ថែទាំ គាំទ្រ និងការរីកលូតលាស់សំរាប់យុវនារី-កុមារីនីមួយៗ។ ដើម្បីស្តារ និងព្យាបាលជនរងគ្រោះពីរបួសស្នាម ឬលក្ខខណ្ឌសុខភាពមិនល្អដែលពួកគាត់បានឆ្លងកាត់នៅក្នុងស្ថានភាពរំលោភបំពាន គឺសុខមាលភាពសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់ពួកគាត់ ហើយសុខមាលភាពរបស់យុវនារី និងកុមារីដែលយើងធ្វើការជាមួយគឺមានសារសំខាន់ណាស់យើងយកចិត្តទុកដាក់យ៉ាងហ្មត់ចត់បំផុត។

ជនរងគ្រោះចូលថ្មីទាំងអស់នៅមណ្ឌលស្តារនីតិសម្បទាទុំឌី  ទទួលបានការពិនិត្យសុខភាពរាងកាយទូទៅ  និងការព្យាបាលបន្ទាន់នៅពេលមកដល់មណ្ឌលភ្លាម  ហើយនឹងទទួលបានការពិគ្រោះជម្ងឺ  និងព្យាបាលបន្តតាមតម្រូវការជាក់ស្តែងរបស់ករណីនីមួយ ៗ ពីវេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកា។

យើងផ្តល់ការពិនិត្យសុខភាពទូទៅដល់យុវនារី-កុមារីដែលយើងធ្វើការជាមួយនៅមណ្ឌលស្តារនីតិសម្បទាទុំឌី មួយឆ្នាំ២ដង។ យើងចាក់វ៉ាក់សាំងបង្ការជម្ងឺផ្សេងៗ ផ្តល់ការថែទាំសុខភាពភ្នែក សុខភាពមាត់ធ្មេញ និងបង្រៀនវគ្គបំណិនជីវិតស្តីពីសុខភាពបឋមដល់យុវនារី-កុមារី។  យើងផ្តល់ការតាមដានការថែទាំសុខភាព  និងព្យាបាលបន្ត  ដល់យុវនារីហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ កុមារីអប់រំសហគមន៍ និស្សិតអាហារូបករណ៍សកលវិទ្យាល័យ និងយុវនារី-កុមារីសមាហរណកម្មក្រោយពីចាកចេញពីមណ្ឌលទៅតាមសហគមន៍វិញ តាមតម្រូវការជាក់ស្តែងរបស់ករណីនីមួយ ៗ ។ យើងធ្វើការបញ្ជូនយុវនារី-កុមារីទៅទទួលការពិគ្រោះជម្ងឺ  និងការព្យាបាលនៅតាមមន្ទីរពេទ្យ/គ្លីនិកឯកទេសតាមតម្រូវការជាក់ស្តែង។ ក្នុងករណីខ្លះ យើងក៏បានផ្តល់ការថែទាំសុខភាពដល់សមាជិកគ្រួសាររបស់យុវនារី-កុមារី។

### ២.១.២ សុខភាពផ្លូវចិត្ត (ចិត្តសាស្រ្ត)

ការជួញដូរផ្លូវភេទ រំលោភសេពសន្ថវៈ ការរំលោភបំពានផ្លូវភេទ ឬការកេងប្រវ័ញ្ចផ្លូវភេទ បានបណ្តាលអោយមានវិបត្តិមហន្តរាយដល់ការអភិវឌ្ឍន៍ជាសកល  ជាពិសេសជនរងគ្រោះដោយអំពើឧក្រិដ្ឋនេះតែងតែជាប់នូវស្លាក់ស្នាមវិប្បដិសារី និងសុខភាពផ្លូវចិត្តធ្ងន់ធ្ងរជាបច្ច័យធ្វើអោយប៉ះពាល់ដល់ការអភិវឌ្ឍន៍រាងកាយនិងស្មារតី។ ដើម្បីជួយជនរងគ្រោះអោយចេញផុតពីស្លាក់ស្នាមវិប្បដិសារី និងសុខភាពផ្លូវចិត្តធ្ងន់ធ្ងរបាន យើងត្រូវការផ្តល់សេវាកម្មស្តារនីតិសម្បទាដែលមានគុណភាពដល់ពួកគាត់  ក្នុងគោលបំណងជួយអោយអតីតជនរងគ្រោះរស់នៅដោយឯករាជ្យ  ជីវិតមានសុវត្ថិភាព និងភាពរីរាយក្រោយពីការស្តារនីតិសម្បទា និងសមាហរណកម្មទៅតាមសហគមន៍វិញ ។

ជនរងគ្រោះចូលថ្មីទាំងអស់នៅមណ្ឌលស្តារនីតិសម្បទាទុំឌី  ទទួលបានការពិនិត្យវាយតំការពិគ្រោះយោបល់ចិត្តសង្គម  ការព្យាបាលបន្ទាន់នៅពេលមកដល់មណ្ឌលភ្លាម  ហើយនឹងទទួលបានការពិគ្រោះយោបល់ចិត្តសង្គមបន្តចាំបាច់តាមតម្រូវការជាក់ស្តែងរបស់ករណីនីមួយ ៗ ពីបុគ្គលិកចិត្តសាស្រ្តរបស់។ យុវនារី-កុមារីស្នាក់នៅក្នុងមណ្ឌលទទួលបានវគ្គហ្វឹកហ្វឺនបន្ត ស្តីពីការថែទាំសុខភាពផ្លូវចិត្តបឋម និងការអប់អប់រំការការពារបង្ការ (PME) ការព្យាបាលសុខភាពផ្លូវចិត្តតាមបែបសិល្បៈ ក្រុមជួយខ្លួនឯង យោគៈ និងសមាធិ។

យើងនៅតែបន្តការជួយ ការតាមដានបន្តការពិគ្រោះយោបល់ចិត្តសង្គម និងការព្យាបាលបន្តដល់យុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅ កុមារីអប់រំសហគមន៍(CBE) និស្សិតអាហារូបករណ៍សកលវិទ្យាល័យ និងយុវនារី-កុមារីសមាហរណកម្ម បន្ទាប់ពីពួកគាត់បានចាកចេញពីមណ្ឌលទៅសហគមន៍វិញ តាមតម្រូវការជាក់ស្តែងរបស់ករណីនីមួយៗ ។ យើងធ្វើការបញ្ជូនយុវនារី-កុមារីទៅព្យាបាលនៅតាមមន្ទីរ/គ្លីនិកឯកទេសតាមតម្រូវការជាក់ស្តែង។ ក្នុងករណីខ្លះ យើងក៏បានផ្តល់ការជួយគាំទ្រ ការពិគ្រោះយោបល់ចិត្តសង្គមដល់សមាជិកគ្រួសាររបស់យុវនារី-កុមារី។

យើងទទួលស្គាល់ថាឥទ្ធិពល នៃការប៉ះដង្ហិចផ្នែកចិត្តសាស្ត្រ គឺបានកាត់ផ្តាច់អំណាចឥទ្ធិពល និងការផ្សាភ្ជាប់ទំនាក់ទំនង ដូច្នេះវិធីសាស្ត្រ នៃការស្តារនីតិសម្បទា យើងផ្តោតការយកចិត្តទុកដាក់លើការកសាងអំណាចឥទ្ធិពលនិងការបង្កើតទំនាក់ទំនងជាថ្មីឡើងវិញ ដល់យុវនារី-កុមារី ដែលយើងធ្វើការជាមួយទាំងនៅក្នុងមណ្ឌល និងតាមសហគមន៍។ យើងផ្តល់ជំនួយការពិគ្រោះយោបល់ដល់យុវនារីនិងកុមារីអំឡុងពេលនីតិវិធីប្រគល់-ទទួល និងគ្រប់ជំហាននៃដំណើរការនីតិវិធីច្បាប់។

បណ្តាញលើកកម្ពស់អតីតជនរងគ្រោះ ដើរតួយ៉ាងសំខាន់ ក្នុងការជួយដល់យុនារី និង កុមារីចូលថ្មីនៅក្នុងមណ្ឌល ក្នុងការបង្កើតភាពជឿជាក់ និង ការកសាងទំនាក់ទំនងជាថ្មីជាមួយមនុស្សជុំវិញខ្លួនឡើងវិញ ។ កម្មវិធីជាច្រើនត្រូវបានបង្កើតឡើង ដោយអនុលោមតាមបទដ្ឋាន និងតាមដំណាក់កាលសំខាន់ៗ ដែលអាចបត់បែនបាន និង យកចិត្តទុកដាក់ខ្ពស់ដល់គ្រប់អតីតជនរងគ្រោះ នៅពេលពួកគាត់មកដល់មណ្ឌលថែទាំ ហើយយើងផ្តល់អាទិភាពទៅតាមតម្រូវការជាក់ស្តែងរបស់បុគ្គលនីមួយៗ ។

**២.១.៣ គាំពារនីតិកម្ម**-កុមារីភាគច្រើន ដែលអង្គការអាហ្វេ-ស៊ីបកម្ពុជា ធ្វើការជាមួយជាជនរងគ្រោះដោយការរំលោភសេពសន្ថវៈ។ ប្រហែល៩០%ជាកុមារីរងគ្រោះដោយការរំលោភសេពសន្ថវៈ និង១០%ទៀតជាកុមារីរងគ្រោះដោយការរំលោភបំពានសិទ្ធិមនុស្សតាមរូបភាពផ្សេងៗ និងជាករណីការពារបង្ការ(មានហានិភ័យ)។ ហេតុដូច្នេះ ជំនួយផ្នែកច្បាប់គឺមានសារសំខាន់ណាស់ ហើយត្រូវការជាចាំបាច់បំផុតសំរាប់ជួយដល់កុមារីរងគ្រោះអោយទទួលបានយុត្តិធម៌និងសំណងរដ្ឋប្បវេណី។ ជនរងគ្រោះទាំងអស់ដែលបញ្ជូនមក អង្គការ អាហ្វេស៊ីប-កម្ពុជា ពាក់ព័ន្ធនីតិវិធីច្បាប់ យើងផ្តល់ជូនជំនួយផ្នែកច្បាប់ និងការគាំទ្រដោយធ្វើការក្នុងភាពជាដៃគូរជាមួយបណ្តាអង្គការផ្សេងៗ ដែលផ្តល់ជំនួយផ្នែកច្បាប់ និងក្រុមហ៊ុនលច្បាប់ សំរាប់ការជួយដល់ជនរងគ្រោះអោយទទួលបានទាំងយុត្តិធម៌ និងសំណងរដ្ឋប្បវេណី។ បុគ្គលិកផ្នែកច្បាប់ធ្វើការសហការជាមួយបណ្តាអង្គការ ក្រសួង/មន្ទីរសង្គមកិច្ច អាជ្ញាធរមូលដ្ឋាន និងបណ្តាភាគីពាក់ព័ន្ធ ក្នុងការទទួលយកជនរងគ្រោះដែលត្រូវការការការពារជាពិសេស មកស្នាក់ក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី ដើម្បីត្រៀមរៀមចំករណីផ្លូវច្បាប់ និងធានាអោយបានគ្រប់ជនរងគ្រោះទាំងអស់ទទួលបាននូវជំនួយផ្នែកច្បាប់ និងមានមេធាវីជាតំណាងការពារក្តីអោយជនរងគ្រោះនូវគ្រប់តំណាក់នៃនីតិវិធីច្បាប់នៅតុលាការ។

## ២.២ កម្មវិធីអប់រំ និងហ្វឹកហ្វឺនជំនាញខាងក្រៅ

ភាគច្រើននៃក្រុមគោលដៅដែលយើងធ្វើការជាមួយជាអ្នកមកពីតាមជនបទដាច់ស្រយាលដែលពិបាកទទួលបានការសិក្សាអប់រំដោយសារភាពក្រីក្រ និងការរស់នៅតាមតំបន់ដាច់ស្រយាល់ឆ្ងាយពីសាលារៀន។ អង្គការអាហ្វេស៊ីប-កម្ពុជាផ្តល់ការអប់រំក្នុងប្រព័ន្ធជា៣ប្រភេទផ្សេងគ្នា ជាអាទិមាន (១)ការអប់រំក្នុងប្រព័ន្ធនៅសាលារដ្ឋ/សាលាសាធារណៈខណ:ដែលកុមារីកំពុងទទួលការថែទាំនៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី (២)ការអប់រំនៅសហគមន៍(CBE)នៅពេលកុមារីបានស្តារនីតិសម្បទា ជាសះស្បើយ និងបានសមាហរណកម្មទៅរស់នៅជាមួយក្រុមគ្រួសារវិញ នៅតាមសហគមន៍

ហើយបន្តការសិក្សាខណៈពួកគាត់កំពុងរស់នៅជាមួយក្រុមគ្រួសាររបស់ពួកគាត់ និង(៣)ថ្នាក់ឧត្តមសិក្សាសំរាប់អាហារូបករណ៍នៅសកលវិទ្យាល័យ។ ស្ថានភាព និងវឌ្ឍនៈភាពនៃការសិក្សារបស់កុមារីទាំងនេះត្រូវបានពិនិត្យតាមដានយ៉ាងទៀងទាត់ដោយយកចិត្តទុកដាក់បំផុត។

បុគ្គលិកធ្វើការវាយតំលៃកុមារីនីមួយៗ នៅពេលពួកគាត់មកដល់មណ្ឌល ថាតើពួកគាត់ចង់ទទួលការអប់រំក្នុងប្រព័ន្ធ ឬហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅនៅសាលាផ្តល់វិជ្ជាជីវៈខាងក្រៅ។

**២.២.១ ការអប់រំក្នុងប្រព័ន្ធខណៈពេលស្នាក់នៅមណ្ឌល**-ចំពោះកុមាររងគ្រោះដែលគ្រប់អាយុរៀននៅសាលាបឋមសិក្សា ទិសដៅចំបងរបស់យើងគឺធានាអោយបានថាពួកគាត់ទទួលបានការអប់រំជាក់លាក់មួយ នៅក្នុងបរិស្ថានសាលាសាធារណៈដែលមានសុវត្ថិភាពមួយ។ ប្រសិនបើកុមារជាក្មេងកំព្រា ឬក៏មិនមានសុវត្ថិភាពពេលនាងត្រឡប់ទៅរស់នៅផ្ទះវិញ យើងផ្តល់ការអប់រំក្នុងប្រព័ន្ធជូនពួកគាត់ខណៈពួកគាត់ស្នាក់នៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី នៅក្នុងរាជធានីភ្នំពេញ។ កុមារីនៅមណ្ឌលទុំឌីទៅរៀននៅសាលាសាធារណៈនៅជិតមណ្ឌលអាចជិះកង់ទៅរៀនដោយសុវត្ថិភាពសំរាប់សាលាបឋមសិក្សា និងយើងមានរថយន្តសំរាប់ជូនកុមារីទៅរៀននៅសាលាអនុវិទ្យាល័យ និងវិទ្យាល័យ។ យើងផ្តល់ការបង្រៀនបន្ថែមតាមការចាំបាច់ជាក់ស្តែងនៅក្នុងមណ្ឌលដល់កុមារី ដើម្បីជួយជំរុញអោយពួកគាត់រៀនទាន់កម្មវិធីសិក្សារបស់សាលា។

**២.២.២ ភាសាអង់គ្លេស កុំព្យូទ័រ និងបណ្ណាល័យ**-យើងផ្តល់ការបង្រៀនភាសាអង់គ្លេស និងកុំព្យូទ័រយ៉ាងទៀងទាត់ដល់កុមារីដែលស្នាក់នៅក្នុងមណ្ឌល និងកុមារីមកពីគ្រួសារក្រីក្រពីសហគមន៍នៅជុំវិញមណ្ឌលទុំឌី ក្នុង១សប្តាហ៍៥ថ្ងៃ ពីច័ន្ទ-សុក្រ ១ថ្ងៃ៥-៦ម៉ោង បែងចែកជា៤-៥ក្រុមក្នុង១ថ្ងៃសំរាប់សិក្សាភាសាអង់គ្លេស និង៤-៥ក្រុមដូចគ្នាសំរាប់សិក្សាកុំព្យូទ័រ ហើយកុមារីទាំងអស់នេះអាចចូលអានសៀវភៅផ្សេងៗនៅក្នុងបណ្ណាល័យ ដែលពោពេញទៅដោយធនធានសំរាប់ការអាននៅក្នុងមណ្ឌលទុំឌី។

**២.២.៣ ការអប់រំសហគមន៍**-យើងលើកកម្ពស់ការចិញ្ចឹមបីបាច់ថែរក្សាកុមារីអោយរស់នៅក្នុងគ្រួសារជាជាងអោយពួកគាត់រស់នៅតាមគ្រឹះស្ថាន ដូច្នេះការធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ គឺជាជំរើសអាទិភាព តាមដែលអាចធ្វើទៅបាន ក្រោយពីយើងទទួលបានការបញ្ជាក់អំពីសុវត្ថិភាព និង សុខមាលភាពរបស់ពួកគាត់ ថាអាចសមារណកម្មបាន យើងឧបត្ថម្ភជាការសិក្សាអប់រំនៅសហគមន៍ ឬ បញ្ជូនទៅសិក្សាជំនាញវិជ្ជាជីវៈនៅខាងក្រៅ ។ ជាជំរើសដ៏ត្រឹមត្រូវបំផុតដែលកុមារីត្រូវបន្តការសិក្សាហើយរស់នៅផ្ទះជាមួយក្រុមគ្រួសារពួកគាត់ យើងឧបត្ថម្ភសម្ភារៈសិក្សា ឯកសណ្ឋានសិស្ស និង ថ្លៃសិក្សា ដើម្បីអោយកុមារីបានចូលរៀន និងការពារពួកគេកុំអោយបោះបង់ការសិក្សាដើម្បីទៅរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ។

**២.២.៤ អាហារូបករណ៍សកលវិទ្យាល័យ**-កុមារីដែលបានប្រឡងបញ្ចប់ថ្នាក់ទី១២ (មធ្យមសិក្សាទុតិយភូមិ) មានសិទ្ធដាក់ពាក្យស្នើសុំអាហារូបករណ៍រៀនបន្តនៅសកលវិទ្យាល័យបាន ។ អង្គការ អាហ្វេស៊ីប កម្ពុជា ជឿជាក់យ៉ាងមុតមាំថា នេះជាពេលវេលាដ៏សំខាន់ ក្នុងការផ្តល់ឳកាសអោយកុមារីបានបន្តការសិក្សា ។ យើងមានផែនការណែនាំអំពីកម្មវិធីជួយដល់ពួកគេដែលបណ្តាអង្គការឬសាធារណៈជនអាចចូលរួមជួយឧបត្ថម្ភគាំទ្រនូវតម្លៃសិក្សារបស់អតីតជនរងគ្រោះ (កុមារី) ណាម្នាក់ ដូចជា ជួយឧបត្ថម្ភថ្លៃសិក្សា ការចាយវាយផ្សេងៗ និង ការជួយលើមុខវិជ្ជាសិក្សាជាក់លាក់ណាមួយរបស់កុមារី ។ យើងរំពឹងថា និស្សិតនឹងតបស្នងមកអង្គការវិញ តាមរយៈផ្តល់ការហ្វឹកហ្វឺនការងារក្រោយពេល

ពួកគេបញ្ចប់ការសិក្សា ដែលអាចជាការផ្តល់ផលប្រយោជន៍បន្ថែម ក្នុងការជំរុញការទទួលខុសត្រូវ និង ការលើកកម្ពស់និរន្តភាពសេដ្ឋកិច្ចរយៈពេលវែង ។

ទិសដៅសំខាន់នៃកម្មវិធីអប់រំក្នុងប្រព័ន្ធដែលយើងផ្តល់អោយ គឺដើម្បីផលិតធនធានមនុស្សដែលមានការអប់រំល្អ និងមានទំនុកចិត្ត អាចសិក្សាអាជីពវិជ្ជាជីវៈ ជាគិលានុបដ្ឋាយិកា អ្នកចិត្តវិទ្យា ហិរញ្ញវត្ថុ និងគណនេយ្យ ពាណិជ្ជកម្មនិង រដ្ឋបាល ការគ្រប់គ្រង នីតិកម្មនិងសេដ្ឋកិច្ច អក្សរសាស្ត្រអង់គ្លេស អក្សរសាស្ត្រខ្មែរ បដិសណ្ឋារកិច្ចនិងទេសចរណ៍ ព័ត៌មានវិទ្យា រដ្ឋបាលសាធារណៈ ទីផ្សារនិងទំនាក់ទំនង ទីផ្សារនិងធនាគារ និងវិស័យដទៃទៀតក្រោយពេលបញ្ចប់ការសិក្សា។

ទិសដៅស្នូលរបស់យើងគឺលើកទឹកចិត្តជនរងគ្រោះ អោយក្លាយជាអតីតជនរងគ្រោះ និងលើកទឹកចិត្តអតីតជនរងគ្រោះ អោយក្លាយជាផ្នែកមួយនៃដំណោះស្រាយ ។ បច្ចុប្បន្ន យើងមានអតីតជនរងគ្រោះដែលបានបញ្ចប់ការសិក្សាពីសកលវិទ្យាល័យកំពុងបំរើការក្នុង អង្គការ អាហ្វេស៊ីប កម្ពុជា ដូចជា ប្រធានមណ្ឌល កម្មវិធីចិត្តសាស្ត្រ កម្មវិធីសុខភាព អប់រំសហគមន៍ កម្មវិធីអាហាររូបករណ៍សកលវិទ្យាល័យ និងហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ ការិយ៉ាល័យរដ្ឋបាលនិង គណនេយ្យ កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច បណ្តាញលើកកម្ពស់អតីតជនរងគ្រោះ ជាបុគ្គលិកថែរទាំ និងចុងភៅជាដើម។

**២.២.៥ ការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ**-អតីតជនរងគ្រោះដែលមានអាយុច្រើនជាទូទៅចាប់ពី១៦ ឆ្នាំឡើងទៅ តែងតែចង់រៀនជំនាញវិជ្ជាជីវៈអោយបានចប់ឆាប់ ៗ តាមតែអាចធ្វើទៅបាន ជាប្រយោជន៍ ដើម្បីអោយពួកគេអាចវិលត្រឡប់ទៅចាប់ផ្តើមការរស់នៅដោយស្វ័យនិរន្តភាព ឬ ជាមួយក្រុមគ្រួសារវិញ ។ ចំណុចសំខាន់នៃការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈ គឺជាប្រភាពចំណូលស្វ័យទ្រទ្រង់ និង ជាបំណិនជីវិតចាំបាច់សំរាប់យុវនារីម្នាក់ ៗ ក្នុងការជួយទ្រទ្រង់ខ្លួនគាត់ និង ក្រុមគ្រួសាររបស់គាត់អោយមានស្ថេរភាព និង ឯករាជ្យភាព ។

យើងផ្តោតសំខាន់លើសារប្រយោជន៍បំណិនជីវិត និង ការបណ្តុះបណ្តាលអំពីរបៀបបង្កើតមុខរបរតាមរយៈភាពជាដៃគូរ ជាមួយបណ្តាអ្នកឯកទេស ដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ និង បណ្តាអង្គការក្រៅរដ្ឋាភិបាលនានា ជាជាងការផ្តល់ការបណ្តុះបណ្តាលផ្ទាល់នៅក្នុងអង្គការ អាហ្វេស៊ីប កម្ពុជា ។ មកដល់ពេលនេះ យើងបានប្រមូលចងក្រងឯកសារ រាយបញ្ជីមុខជំនាញវិជ្ជាជីវៈផ្សេងៗ បានជាង៣០មុខវិជ្ជា (បញ្ជីរាយមុខជំនាញវិជ្ជាជីវៈបណ្តុះបណ្តាលខាងក្រៅ) ដូចជា ជំនាញអ៊ុតសក់ កាត់ដេរ ធ្វើនំ ភោជនីយដ្ឋាន បដិសណ្ឋារកិច្ច ។ល។ ទិសដៅសំខាន់បំផុត គឺជួយអោយពួកគាត់មានលទ្ធភាពសំរេចបានឯករាជ្យភាពសេដ្ឋកិច្ច និង សេចក្តីថ្លៃថ្នូរនៅពេលពួកគាត់ត្រឡប់ទៅសហគមន៍វិញ។ យន្តការទាំងនេះ គឺបើម្បីពន្លឿននីតិវិធី បង្កលទ្ធភាពអាចធ្វើសមាហរណកម្មយុវនារី និង កុមារីនីមួយ ៗ បានលឿន តាមដែលអាចធ្វើទៅបាន ។

**២.៣ កម្មវិធីលើកកំពស់សេដ្ឋកិច្ច (សមាហរណកម្ម)**

យុវនារី ឬ កុមារី ដែលមានវឌ្ឍនភាពលើការស្តារនីតិសម្បទា ការអប់រំ និង បណ្តុះបណ្តាល យើងអាចចាប់ផ្តើមនីតិវិធីធ្វើសមាហរណកម្មពួកគាត់ត្រឡប់ទៅកាន់ជីវិតធម្មតាវិញ។ នីតិវិធីនេះពាក់ព័ន្ធនិងការធ្វើជាកូនជាង ឬ ជាអ្នកហ្វឹកហ្វឺនការងារនៅកន្លែងណាមួយ ។ ពួកគាត់រៀនរស់នៅដោយម្ចាស់ការលើខ្លួនឯង (ឯករាជ្យ) គ្រប់គ្រង ចាត់ចែងការចាយវាយលុយកាក់ផ្ទាល់ខ្លួន និង ធានាអោយបានថា ពួកគាត់អាចចូលរួមចំណែកបានដោយប្រក្រតីក្នុងការប្រើប្រាស់អាជីពដែលពួកគាត់បានជ្រើសរើស។

សមាហរណកម្ម ជាការងារដែលពាក់ព័ន្ធ ការស្រាវជ្រាវស្វែងរកក្រុមគ្រួសារ ការទៅលេងគ្រួសារ ការសិក្សាវាយតំលៃស្ថានភាពគ្រួសារ និង ឯកភាពវូប្បនីយកម្ម (ការសំរុះសំរួល) ការសិក្សាវាយតំលៃសហគមន៍ ការជួយគាំទ្រសកម្មភាពរកប្រាក់ចំណូលផ្សេង ៗ សំរាប់គ្រួសាររបស់យុវនារីនិងកុមារី ការធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសកំណើតវិញតាមតម្រូវការជាក់ស្តែង និងការតាំងទីលំនៅដោយឯករាជ្យនៅតាមសហគមន៍។

ចំពោះយុវនារី ដែលបានប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិ នេះជាពេលដែលត្រូវចាប់ផ្តើមអាជីពរបស់ពួកគាត់ ឬ ត្រូវរៀនបន្តនៅសកលវិទ្យាល័យ ។ អន្តរកាលរបស់ពួកគាត់នេះគឺមានសារៈសំខាន់ណាស់ តម្រូវអោយមានការគ្រប់គ្រងដោយប្រុងប្រយ័ត្ន ដើម្បីធានាអោយបានថាពួកគាត់អាចរស់បានដោយមាននិរន្តភាពលើជីវិតផ្ទាល់ខ្លួនរបស់ពួកគាត់។

ដើម្បីធានាអោយបាន នូវការបន្តភាពជោគជ័យរបស់អតីតជនរងគ្រោះ ដែលបានស្តារនីតិសម្បទា និង រៀនចប់កម្មវិធីផ្សេង ៗ តម្រូវអោយបុគ្គលិកកម្មវិធីលើកកំពស់សេដ្ឋកិច្ច ធ្វើការតាមដានបន្តទៅលើអតីតជនរងគ្រោះ ក្រោយពីការធ្វើសមាហរណកម្មរួចហើយ សំរាប់រយៈពេលមួយដោយគ្មានកំណត់ តាមស្ថានភាពជាក់ស្តែងរបស់ករណីនីមួយ ៗ ។ បុគ្គលិកតាមដានបន្តពីភាពជោគជ័យរបស់កម្មវិធី ដោយការធ្វើរបាយការណ៍អំពីប្រភពចំណូល-ចំណាយរបស់យុវនារី និង អំពីស្ថានភាពផ្សេង ៗ របស់ពួកគាត់ (ឧ. ហានិភ័យ ឱនភាព និរន្តរភាព និង ភាពជោគជ័យ)។

ប្រហាក់ប្រហែលគ្នានិងកម្មវិធីជួយឧបត្ថម្ភថ្លៃសិក្សាសំរាប់អតីតជនរងគ្រោះណាម្នាក់នៅឧត្តមសិក្សាដែលយើងបានបរិយាយខាងលើ យើងស្វែងរកមូលនិធិដើម្បីជួយផ្តល់ឱកាសដល់យុវនារី ដែលចង់ធ្វើការនៅកន្លែងអង្គការណាមួយ ដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ បានធ្វើការជាមួយនិយោជកល្អត្រឹមត្រូវ និង មានសុវត្ថិភាព គឺជួយដល់យុវនារីដែលបានបញ្ចប់ការសិក្សាអោយទទួលបានឱកាសល្អ ដើម្បីអភិវឌ្ឍន៍វិជ្ជាជីវៈរបស់ខ្លួនអោយទទួលបានជោគជ័យ។

យើងបានចងក្រងក្រុមការងារ ដោយធ្វើការជាមួយបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ (SEN) ដើម្បីជួយដល់អតីតជនរងគ្រោះអោយទទួលបានសក្តានុពលខ្ពស់ឆ្ពោះទៅរកភាពជោគជ័យ ទោះបីជាគាត់ចាប់ផ្តើមមុខរបរផ្ទាល់ខ្លួន ឬ បំរើការអោយគេក៏ដោយ។ ជាការពិត យើងមិនបានផ្តល់ការអប់រំ និង បណ្តុះបណ្តាលអោយពួកគាត់បានគ្រប់គ្រាន់នោះទេ ដូច្នេះសមាជិកបណ្តាញក្រុមសម្លេងដើម្បីផ្លាស់ផ្តូរ ធ្វើការជាមួយយុវនារីនីមួយ ៗ ដែលបានបញ្ចប់ការសិក្សាដើម្បីធានាអោយទទួលបានលទ្ធផលល្អប្រសើរនាពេលអនាគត។

**ការតាមដានបន្តក្រោយពេលធ្វើសមារណកម្ម**-ការតាមដានបន្តចំពោះយុវនរី និង កុមារីដែលបានសមាហរណកម្មរួចហើយ គឺមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការផ្តល់ការគាំទ្រ ផ្តល់ដំបូន្មាន ដើម្បីអោយការធ្វើសមាហរណកម្មទទួលបានជោគជ័យ ផ្តល់ការឧបត្ថម្ភបន្ថែមតាមតម្រូវការជាក់ស្តែង ចុះសួរសុខទុក្ខ ពិនិត្យតាមដាន អំពីស្ថានភាពផ្សេងៗ ។

គោលដៅសំខាន់ គឺជួយអោយយុនារីនីមួយ ៗ សំរេចបានស្វ័យឯករាជ្យភាព ព្រោះដំណាក់កាលនេះយុវនារី ដែលបានទទួលផលពីកម្មវិធី មិនពឹងផ្អែកលើការជួយជ្រោមជ្រែងពីអង្គការទៀតនោះទេ ព្រោះពួកគាត់អាចមានលទ្ធភាពជួយសង្គមវិញ តាមរយៈការជួយយុវនារីដទៃទៀត ដែលកំពុងត្រៀមខ្លួនឆ្ពោះមកកាន់ដំណាក់កាលនេះដែរ ។ យើងបានបង្រៀនពួកគាត់ អំពីសារៈសំខាន់ នៃគណនេយ្យភាព និង ទំនួលខុសត្រូវរបស់បុគ្គលម្នាក់ ៗ ក្នុងអំឡុងពេលដែលពួកគាត់ស្នាក់នៅអាហ្វេស៊ីបកម្ពុជា ដូច្នេះពួកគាត់រីករាយក្នុងការជួយមកអង្គការវិញ ។ ការជួយមកអង្គការវិញ អាចក្នុងរូបភាពជាការជួយដល់អតីតជនរងគ្រោះដទៃទៀត នៅខណៈពេលពួកគាត់ចាប់ផ្តើមបង្កើតមុខរបរថ្មី ឬ ជាតម្លៃសម្ភារៈសំ

រាប់បង្កើតមុខរបរដែលជាផ្នែកមួយនៃនីតិធីសមាហរណកម្មយើងត្រូវផ្តល់ជូនគាត់ និងចូលជាសមាជិករបស់បណ្តាញលើកកម្ពស់អតីតជនរងគ្រោះ ( SEN ) ។

បុគ្គលិកក្រុមការងារធ្វើការជាមួយយុវនារី ដើម្បីធានាអោយបានថាយុវនារី ដែលបានបញ្ចប់ការសិក្សា បានរៀនអំពីតម្លៃស្វ័យវិនិយោគ (វិនិយោគលើខ្លួនឯង) និង គុណតម្លៃនៃការចែករំលែកតាមរយៈការជួយសង្គមវិញ ជាដំបូងត្រូវធ្វើអោយជីវិតខ្លួនឯងមានលំនឹងជាមុនសិន ដោយបុគ្គលិកក្រុមការងារយើងជួយអោយពួកគាត់ទទួលបានភាពជោគជ័យ និង ធ្វើអោយប្រសើរឡើង នូវស្ថានភាពសេដ្ឋកិច្ចរបស់ពួកគាត់ដែលរស់នៅតាមសហគមន៍។ ការជួយពួកគាត់អោយទទួលបានជោគជ័យ គឺការជួយដល់យុវនារីដ៏ទៃទៀត ដែលកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មវិធីនៅឡើយ និងធ្វើការតស៊ូមតិសំរាប់យុវនារី និង កុមារីដ៏ទៃទៀត។

យើងតែងតែប្រារព្ធធ្វើសិក្ខាសាលាប្រចាំឆ្នាំ ស្តីពីការចែករំលែក និង ការឆ្លុះបញ្ចាំង យ៉ាងហោចណាស់មួយឆ្នាំម្តងជាមួយអតីតជនរងគ្រោះ ដែលកំពុងស្នាក់នៅក្នុងមណ្ឌលត្រៀមធ្វើសមាហរណកម្ម និងអតីតជនរងគ្រោះដែលបានធ្វើសមាហរណកម្មរួចហើយ ក្នុងគោលបំណងចែករំលែកបទពិសោធន៍ អំពីភាពជោគជ័យនៃការកសាងជីវិតថ្មីក្នុងសង្គម។

## ២.៤ កម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ (SEN)

កម្មវិធីបណ្តាញការងារលើកកម្ពស់អឌីតជនរងគ្រោះ គឺជាការប្រមូលផ្តុំអឌីតជនរងគ្រោះមួយក្រុម ដែលជាអ្នកទទួលផលពីកម្មវិធីអង្គការអាហ្វេស៊ីប-កម្ពុជា បានទទួលស្តារនីតិសម្បទា ដោយជោគជ័យពីរបួសស្នាមផ្លូវកាយ និងផ្លូវចិត្ត ហើយបានធ្វើសមាហរណកម្មទៅតាមបណ្តាសហគមន៍វិញ នៅទូទាំងប្រទេសកម្ពុជា ក្នុងគោលបំណងលើកកម្ពស់សុខមាលភាពសង្គម អឌីតជនរងគ្រោះ ដោយហឹង្សាផ្លូវភេទ ការជួញដូរ រំលោភបំពាន ឬកេងប្រវ័ញ្ចផ្លូវភេទ។

កម្មវិធីបណ្តាញការងារលើកកម្ពស់អឌីតជនរងគ្រោះ សំរេចការងារនេះបាន តាមរយៈការអនុវត្តសកម្មភាពសហសម្លេង និងបន្តជួយដល់សមាជិកក្រុមដែលងាយរងគ្រោះ ពីគ្រប់ទំរងនៃស្ថានភាពលំបាកដែលបង្កគ្រោះថ្នាក់ដល់អាយុជីវិតរបស់ពួកគេនៅតាមសហគមន៍ ។

កម្មវិធីបណ្តាញការងារលើកកម្ពស់អឌីតជនរងគ្រោះ ក៏បានធ្វើការបញ្ជ្រាបការយល់ដឹងដល់សាធារណៈជនទូទៅ ដើម្បីស្វែងរកដំណោះស្រាយអោយបានប្រសើរឡើង។ សមាជិកនីមួយ ៗ ដើរតួនាទីយ៉ាងសំខាន់ជាអ្នកធ្វើការផ្លាស់ប្តូរនៅក្នុងសហគមន៍របស់ពួកគាត់ ដោយការពាំនាំនូវសម្លេងជនរងគ្រោះអោយបានឮដល់ស្ថាប័នពាក់ព័ន្ធ។

បណ្តាញការងារនេះ ដឹកនាំ និងគ្រប់គ្រងដោយអឌិតជនរងគ្រោះ ដោយការជួញដូរមនុស្សឆ្លងដែន តែដោយធនធានមានកំណត់ កម្មវិធីនេះត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយបណ្តាកម្មវិធីផ្សេង ៗ ក្រោយពីការស្តារនីតិសម្បទា ដូចជាកម្មវិធីសុខភាព ចិត្តសាស្រ្ត អាហារូបករណ៍សកលវិទ្យាល័យនិងហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ អប់រំសហគមន៍ និងលើកកម្ពស់សេដ្ឋកិច្ច ដើម្បីស្វែងរកដំណោះស្រាយនៃតម្រូវការអោយជនរងគ្រោះ និងអឌីតជនរងគ្រោះ ក្នុងន័យបំរើអោយការរួមបញ្ចូលសមូហសម្លេងជាមួយសកម្មភាពគោលដៅ ស្របជាមួយទិសដៅស្នូលដែលបានចែងថា *“លើកកម្ពស់ជនរងគ្រោះអោយទៅជាអឌីតជនរងគ្រោះ ហើយលើកកម្ពស់អឌីតជនរងគ្រោះអោយទៅជាផ្នែកមួយនៃដំណោះស្រាយ”* ព្រោះថាអឌីតជនរងគ្រោះ គឺជាអ្នកផ្លាស់ប្តូរដ៏ឈ្លាសវៃអស្ចារ្យនៅក្នុងវិស័យការងារនេះ ហើយពួកគាត់ជាគំរូដ៏ល្អសំរាប់អោយជនរងគ្រោះដ៏ទៃទៀតអាចយកគំរូតាមពួកគាត់បាន។

នៅក្នុងឆ្នាំ២០២១ ៣៧%នៃបុគ្គលិកអង្គការអេកម្ពុជា គឺជាអតីតជនរងគ្រោះដែលកំពុងបំរើការនៅតាមបណ្តាកម្មវិធីស្នូលទាំង៧ រួមមានកម្មវិធី ស្តារនីតិសម្បទា សុខភាព ចិត្តសាស្ត្រ អាហារូបករណ៍សកលវិទ្យាល័យនិងហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ អប់រំសហគមន៍ លើកកម្ពស់សេដ្ឋកិច្ច និងបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ។ អតីតជនរងគ្រោះរបស់យើងត្រូវបានលើកកម្ពស់ជាបុគ្គលសំខាន់ នៅក្នុងជួថ្នាក់ដឹកនាំគ្រប់កំរិត និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់អង្គការ ។

## III. សុច្ឆន:ករវំពឹងទុក និង លទ្ធផលសំរេចបាន

### ៣.១ របាយការណ៍សង្ខេប

ការធ្វើការជាមួយជនរងគ្រោះ ដោយអំពើហឹង្សាផ្លូវភេទ ជួញដូរ រំលោភបំពាន ទាសភាពជាប់កិច្ចសន្យា ឬ ការកេងប្រវ័ញ្ចផ្លូវភេទ គឺមានការស្មុគស្មាញខ្លាំងណាស់ ដែលតម្រូវអោយអង្គការ អាហ្វេស៊ីប កម្ពុជា ធ្វើការជាអន្តរកម្មវិធី ដើម្បីផ្តល់សេវាកម្មដល់ជនរងគ្រោះតាមតម្រូវការចាំបាច់ និង តាមឆន្ទៈរបស់ពួកគាត់ ដោយការចាប់ផ្តើមពីការកំណត់អត្តសញ្ញាណជនរងគ្រោះ រហូតដល់ ការធ្វើសមាហរណកម្មអតីតជនរងគ្រោះ ទៅកាន់សហគមន៍វិញ។ ស្ថាបនិក និងនាយិកាគ្រប់គ្រងរបស់យើង លោកស្រី **សុម៉ាលី ម៉ម** បានមានប្រសាសន៍ថា *“ យើងចំណាយពេល៥នាទីសង្គ្រោះកុមារម្នាក់ ប៉ុន្តែយើងត្រូវការពេលវេលារាប់ឆ្នាំ ដើម្បីស្តារនីតិសម្បទាកុមារម្នាក់ អោយជាសះស្បើយពីរបួសផ្លូវកាយ និង របួសផ្លូវចិត្តដែលកុមារបានឆ្លងកាត់ ”*។

នេះជាការអនុវត្តបន្តនូវសកម្មភាពកម្មវិធីដែលមានស្រាប់ ដូច្នេះរបាយការណ៍ប្រចាំឆ្នាំ២០២១នេះ យើងផ្តោតតែលើសកម្មភាពកម្មវិធីដែលសម្រេចបាន ប្រៀបធៀបជាមួយសុច្ឆន:ករវំពឹងទុក ដែលយើងបានចងក្រងនៅក្នុងផែនការមេដែលប្រធានកម្មវិធីនីមួយ ៗ បានធ្វើបទបង្ហាញនៅថ្ងៃទី២៣-២៥ ខែវិច្ឆិកា ឆ្នាំ២០២០ និងបានទទួលការអនុម័ត ឯកភាពពីក្រុមប្រឹក្សាភិបាលប្រតិបត្តិរបស់អង្គការ អាហ្វេស៊ីប កម្ពុជា។

លទ្ធផលសំរេចបាននៅក្នុងរបាយការណ៍នេះ គឺជាលទ្ធផលនៃការអនុវត្តរួម ចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ បានទទួលការឧបត្ថម្ភហិរញ្ញវត្ថុ ពីបណ្តាម្ចាស់មូលនិធិ និង អ្នកគាំទ្រដែលបានឧបត្ថម្ភដល់កម្មវិធីផ្សេង ៗ តាមទិសដៅរបស់ខ្លួន ប៉ុន្តែជាវិភាគទានរួមដែលនាំអោយសំរេចបាននូវលទ្ធផលរួមនៃបណ្តាកម្មវិធីរបស់អង្គការ អាហ្វេស៊ីបកម្ពុជាទាំងអស់សំរាប់រយៈពេល១២ខែក្នុងឆ្នាំ២០២១។

### ៣.២ អ្នកទទួលផលគំរោង

យើងអនុវត្តសកម្មភាពការងារ ដោយអនុលោមទៅតាមគោលដៅ និង ទិសដៅទាំងឡាយ ដែលបានដាក់ចេញ ប៉ុន្តែសកម្មភាពមួយចំនួនយើងមិនអាចអនុវត្តមានតាមផែនការដែលយើងបានដាក់ចេញទេ ដោយសារផលប៉ះពាល់នៃឥទ្ធិពលរាតត្បាតរបស់មេរោគកូវីដ១៩ ហើយយើងកំពុងបានផ្តល់អទិភាពចំបងទៅលើការការពារអាយុជីវិតរបស់យុវនារី-កុមារីដែលកំពុងស្នាក់នៅក្នុមណ្ឌលទុំឌី ដោយអង្គការ អាហ្វេស៊ីប កម្ពុជា បានពិនិត្យរៀបចំយុទ្ធសាស្ត្រប្រតិបត្តិការរបស់ខ្លួនឡើងវិញ ដោយការបន្តកាត់បន្ថយគំរោងថវិកា និង សកម្មភាពកម្មវិធីខ្លះដែលមិនចាំបាច់ដូចជា ការជួលគ្រូបង្រៀនរបាំប្រពៃណីជាតិខ្មែរ សកម្មភាពហ្វឹកហ្វឺនយោគ: តែក្វាន់ដូនៅក្នុងមណ្ឌលជាបណ្តោះអាសន្ន ការរៀនគួសំរាប់ថ្នាក់ទី៦ ៩ និង ១២ ដើម្បីសុវត្ថិភាព និស្សិតអាហារូបករណ៍ត្រូវស្នាក់នៅ ហូបចុកនិងរៀនតាមអនឡាញនៅក្នុងមណ្ឌល កាត់ការចុះបេសកម្មមិនចាំបាច់ ។ល។

ដើម្បីការពារការឆ្លងមេរោគគូវីដ១៩ យើងបានផ្អាកសកម្មភាពមួយចំនួនមួយរយៈដូចជា ការទទួលយកកុមារីចូលថ្មី កុមារីទៅចូលឆ្លើយបំភ្លឺ និង ចូលរួមសវនាការនៅតុលាការ សមាហរណកម្មកុមារីត្រឡប់ទៅរស់នៅជាមួយក្រុមគ្រួសារវិញ បញ្ជូនកុមារីទៅពិនិត្យសុខភាព ធ្វើតេស្តសុខភាពនៅខាងក្រៅ ផ្អាកសកម្មភាពហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ កុមារីទៅលេងគ្រួសារនៅតាមសហគមន៍ គ្រួសារមកលេងកុមារីនៅមណ្ឌល និងបុគ្គលិកទៅចូលរួមប្រជុំនៅខាងក្រៅមិនចាំបាច់។

ដើម្បីសុវត្ថិភាព ការពារការឆ្លងមេរោគគូវីដ១៩ កុមារី និងនិស្សិតអាហារូបករណ៍ទាំងអស់ត្រូវបានដាក់អោយនៅក្នុងមណ្ឌល ទុំឌី ជាកន្លែងសុវត្ថិភាព និងជាកន្លែងដែលពួកគាត់អាចប្រើអ៊ិនធើណែតរៀនតាមអនឡាញបាន។ បាញ់អាលកុលសម្លាប់មេរោគក្នុងបរិវេណទីធ្លាមណ្ឌល កន្លែងចំអិននិងទទួលទានអាហារ បន្ទប់គេងរបស់កុមារី បំពាក់អំពូលកាំរស្មីយូវីតាមបន្ទប់គេងរបស់កុមារី ថ្នាក់រៀន បន្ទប់ធ្វើការ និងការិយាល័យបុគ្គលិក ហើយកុមារី និង បុគ្គលិកទាំងអស់ត្រូវអនុវត្តកម្លាតសង្គម និង គោលការន៍អនាម័យអោយបានតឹងរឹងបំផុត ដូចជា ការវាស់កំដៅស៊ីតុណ្ហភាពបុគ្គលិកមុនពេលចូលធ្វើការ ពាក់ម៉ាស់មុខ បាញ់អាលកុលលើសំលៀកបំពាក់និងសម្ភារៈប្រើប្រាស់ និង ត្រូវសំអាតដៃដោយការប្រើជែល ឬ អាលកុលសម្លាប់មេរោគ អោយបានញឹកញាប់បំផុត តាមតែអាចធ្វើបាន នៅពេលចាំបាច់ដែលពួកគាត់ត្រូវចេញទៅក្រៅ ហើយកុមារីដែលឈឺបានដាក់នៅបន្ទប់ដាច់ដោយឡែក។ល។ យើងបានខិតខំប្រឹងប្រែងការពារណាស់ដែរតែនៅតែមានយុវនារី-កុមារីចំនួន១៥នាក់ និងបុគ្គលិកចំនួន៥នាក់ បានឆ្លងមេរោគកូវីដ១៩ នៅក្នុងឆមាសទី២ ឆ្នាំ ២០២១ ដើម្បីការពារការចម្លងរីករាលដាល ជាពិសេសការពារការឆ្លងពីបុគ្គលិកទៅសមាជិកក្រុមគ្រួសាររបស់ពួកគាត់ និងងាយស្រួលក្នុងការគ្រប់គ្រង យើងបានប្រមូលបុគ្គលិកទាំងអស់អោយធ្វើចត្តាឡីស័កនៅក្នុងមណ្ឌលទុំឌី។

ការងាររបស់យើង គឺសង្គ្រោះជីវិតមនុស្ស និងកសាងអនាគតអោយល្អប្រសើរសំរាប់យុវនារី-កុមារីដែលយើងធ្វើការជាមួយ។ ឆ្នាំ២០២១ មានយុវនារី-កុមារី ចំនួន៣៣១នាក់ (៣៩៣-៦២)បានទទួលសេវាកម្ម និង ការថែទាំពីអង្គការ អាហ្វេស៊ីប កម្ពុជា ដូចបានបង្ហាញជូនក្នុតារាងខាងក្រោមនេះ។

| ស្ថិតិកុមារីបានទទួលសេវាកម្មក្នុងឆ្នាំ២០២១ | | | | ស្ថិតិកុមារីដែលបានការចាកចេញ និង ទទួលការថែទាំបន្ត | |
|---|---|---|---|---|---|
| ការពិពណ៌នា | សល់ពីឆ្នាំ២០២០ | ចូលថ្មី ២០២១ | សរុប | ចាកចេញឆ្នាំ២០២១ | ទទួលការថែទាំបន្តឆ្នាំ២០២២ |
| ទទួលការថែទាំក្នុងមណ្ឌល | ៦៣ | ២៧( ៤re-admitted ) | ៩០ | ១៨ | ៧២ |
| ទទួលការអប់រំក្នុងប្រព័ន្ធនៅមណ្ឌល | ៥៦ | ៦ | ៦២ - | ៩(7 CBE & 2 Bac II exam) | ៥៣ - |
| ទទួលជំនាញបណ្តុះបណ្តាលខាងក្រៅ | ៤ | ១១ | ១៥ | ៥(graduated 3 & dropped out2) | ១០ |
| ទទួលការសិក្សាអប់រំនៅសហគមន៍ | ៥០ | ៨ | ៥៨ | ៩* | ៤៩ |
| អាហារូបករណ៍សិក្សានៅសកលវិទ្យាល័យ | ៩ | ៣ (1 in-centered 2 CBE) | ១២ | ០ | ១២ |
| សមាហរណកម្មឧបត្ថម្ភមុខរបរ និ ងការងារ | ០ | ៤(Job employment) | ៤ | ០ | ៤ |
| បណ្តាញលើកកម្ពស់អតីតជនរងគ្រោះ | ០ | ២១ | ២១ | ០ | ២១ |
| ករណីសមាហរណកម្មដាមតានបន្ត | ១២៥ | ៦ | ១៣១ | ០ | ១៣១ |
| សរុប | ៣០៧ | ៨៦ | ៣៩៣ | ៤១ | ៣៥២ |

៩*: មានកុមារីអប់រំសហគមន៍ចំនួន៥នាក់ (KC-0090 PP-3353 PP-3380 PP-3437 និងSR-0518) បានបោះបង់ការសិក្សាដោយមូលហេតុផ្សេងៗ ដូចជា រៀបអាពាហ៍ពិពាហ៍ ធ្វើការរកចំណូលផ្គត់ផ្គង់គ្រួសារ ។ល។ ( KC-0041 ) បានស្នើរសុំមិនទទួលយកការឧបត្ថម្ភការសិក្សាពីអង្គការ អាហ្វេស៊ីប-កម្ពុជា ដោយហេតុថាក្រុមគ្រួសាររបស់គាត់មានលទ្ធភាពទំនុកបំរុងគាត់អោយបន្តឧត្តម្ភសិក្សានៅសកលវិទ្យាល័យនៅរាជធានីភ្នំពេញបាន និង៣នាក់ទៀត (KC-0090, PP-3353 and PP-3396) បានចូលហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ។

## ៣.៣ អំពីបុគ្គលិក និង ការគ្រប់គ្រងគំរោង

យើងមានបុគ្គលិកសរុបចំនួន២៦នាក់ (រាប់បញ្ចូលទាំងបុគ្គលិកធ្វើការពាក់កណ្តាលពេលចំនួន២នាក់) បានបំរើការនៅអង្គការ អាហ្វេស៊ីប កម្ពុជា នៅក្នុងឆ្នាំ២០២១នេះ។ បុគ្គលិកធ្វើការពាក់កណ្តាលពេលចំនួន២នាក់ (១នាក់ជាគ្រូពេទ្យ (វេជ្ជបណ្ឌិត) និង ១នាក់ទៀតជាបុគ្គលិកផ្នែកព័ត៌មានវិទ្យា/ស្ថិតិ) ២២នាក់ជាបុគ្គលិកប្រតិបត្តិការកម្មវិធី និង ៤នាក់ទៀតជាបុគ្គលិកគាំទ្រកម្មវិធី រួមមាន ស្ថាបនិកនិងនាយិការគ្រប់គ្រង (Founder and Managing Director (MD) ១រូប នាយិការប្រតិបត្តិការ (Operation Director (OD) ១រូប នាយកកម្មវិធី (Program Director (PD) ១រូប និង រដ្ឋបាល និង គណនេយ្យករ (Admin and accountant) ១រូប) ។

គោលដៅសំខាន់របស់យើង គឺជួយលើកទឹកចិត្តជនរងគ្រោះ អោយក្លាយជាអតីតជនរងគ្រោះ និងលើកទឹកចិត្តអតីតជនរងគ្រោះ អោយក្លាយទៅជាផ្នែកមួយ នៃដំណោះស្រាយ។ ក្នុងន័យនេះយើងបានដាក់ចេញនូវចក្ខុវិស័យជាក់លាក់មួយក្នុងរយៈពេល១០ឆ្នាំទៀត ចាប់ពីឆ្នាំ២០១៨-២០២៨ បុគ្គលិក៩០%គឺជាអតីតជនរងគ្រោះ។ បច្ចុប្បន្ន យើងមានបុគ្គលិកចំនួន៣៧%នៃចំនួនបុគ្គលិកទាំង២៦នាក់ ជាអតីតជនរងគ្រោះ កំពុងបំរើការនៅតាមកម្មវិធីផ្សេង ៗ ដូចជា កម្មវិធីស្តារនីតិសម្បទា ថែទាំសុខភាព ចិត្តសាស្រ្ត អាហារូបករណ៍សកលវិទ្យាល័យនិងហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ អប់រំសហគមន៍ លើកកម្ពស់សេដ្ឋកិច្ច (សមាហរណកម្ម) បណ្តាញលើកកម្ពស់អតីតជនរងគ្រោះ និងការិយ៍យរដ្ឋបាល និងគណនេយ្យ ។

យើងបានរៀបចំប្រជុំប្រចាំសប្តាហ៍ និង ប្រចាំខែយ៉ាងទៀងទាត់ ជាមួយបុគ្គលិកប្រតិបត្តិការកម្មវិធីទាំងអស់ នៅមណ្ឌលទំុឌី ក្នុងគោលបំណងចែករំលែករបាយណ៍របស់កម្មវិធីនីមួយ ៗ ទទួលយកការឆ្លើយតបនូវការតាមដានសកម្មភាព ពីអង្គប្រជុំពេលមុន ៗ ទទួលយកវឌ្ឍនភាពថ្មី បង្កើតឧបករណ៍ ឬ ក្រុមការងារតាមតម្រូវការជាក់ស្តែង និងដាក់ចេញផែនការសកម្មភាពដែលត្រូវធ្វើបន្តទៀត ។ល។ ការប្រជុំជាផ្នែកមួយនៃការជំរុញវឌ្ឍនភាព ការកសាងស្មារតីការងារជាក្រុម កសាងសមត្ថភាពបុគ្គលិក និង ការគ្រប់គ្រង តាមស្ថានភាព និង ការអនុវត្តជាក់ស្តែង។

ជារៀងរាល់ខែ ប្រធានកម្មវិធីនីមួយ ៗ ត្រូវធ្វើផែនការសកម្មភាព និង គំរោងថវិកាប្រចាំខែ សំរាប់ការអនុវត្តសកម្មភាពកម្មវិធីរបស់ខ្លួន ដាក់ជូនប្រធានខ្សែបណ្តោយតាមសារអេឡិចត្រូនិក(អ៊ីម៉ែល) ដើម្បីពិនិត្យសំរេចជារៀងរាល់ថ្ងៃទី២៥នៃខែនីមួយ ៗ និង ត្រូវធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែដាក់ជូនប្រធានខ្សែបណ្តោយតាមសារអេឡិចត្រូនិក(អ៊ីម៉ែល) ជារៀងរាល់សប្តាហ៍ទី១ នៃខែបន្ទាប់។ ជារៀងរាល់សប្តាហ៍ទី៤ នៃខែនីមួយ ៗ បុគ្គលិករបស់កម្មវិធី នីមួយ ៗ ត្រូវកត់ត្រាទិន្នន័យ ឬ កំណត់ហេតុការងារ របស់ខ្លួនចូលក្នុងសៀវភៅឯកសារ (paper file) ដើម្បីបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកំព្យូទ័រ សំរាប់ធ្វើរបាយការណ៍ផ្ទៃក្នុង (internal) និង របាយការណ៍ធ្វើចេញក្រៅ (external) តាមតម្រូវការជាក់ស្តែង។ បុគ្គលិកផ្នែកតាមដានការសិក្សាអប់រំរបស់យើង ជាអ្នកបញ្ចូលទិន្នន័យដែលបានកត់ត្រានៅលើសៀវភៅឯកសារទាំងអស់ ចូលទៅក្នុងប្រព័ន្ធទិន្នន័យកំព្យូទ័ររបស់កម្មវិធីនីមួយ ៗ ហើយប្រធានផ្នែកព័ត៌មានវិទ្យា/ទិន្នន័យ ជាអ្នកត្រួតពិនិត្យ និង កែតម្រូវរាល់ទិន្នន័យតាមផ្ទៃដែលមានកំហុសឆ្គង។

ឥទ្ធិពលនៃការរីករាលដាលមេរោគកូវីដ-១៩ យើងបានបន្តផ្អាកសកម្មភាពមួយចំនួនដូចឆ្នាំមុន មានជាអាទិការជួលគ្រូបង្ហាត់របាំប្រពៃណីខ្មែរ គ្រូបង្ហាត់យោគៈ សកម្មភាពហាត់កីឡាតែខ្វាន់ដូដល់កុមារីនៅក្នុងមណ្ឌល និស្សិតអាហារូបករណ៍៦នាក់មកស្នាក់នៅក្នុងមណ្ឌលស្តារនីតិសម្បទាទំុឌីដែលពួកគាត់ទទួលបានអាហារ កន្លែងស្នាក់នៅ និងសិក្សាតាមអនឡាញ និងបេសកកម្មមិនចាំបាច់មួយចំនួន ដូចជា ការទទួលកុមារីរងគ្រោះថ្មីចូលមណ្ឌល (លើក

លែងតែករណីពិសេស) ការឡើងតុលាការរបស់កុមារីដើម្បីឆ្លើយបំភ្លឺនិងចូលរួមសវនកា ការធ្វើសមាហរណកម្មកុមារីត្រឡប់ទៅគ្រួសារវិញ ការបញ្ជូនកុមារីទៅពិនិត្យសុខភាពនៅខាងក្រៅ និងការបញ្ជូនបុគ្គលិកទៅចូលរួមប្រជុំនៅខាងក្រៅដែលមិនចាំបាច់ ជាដើម។

ដើម្បីការពារការឆ្លងមេរោគកូវីដ-១៩ កុមារី និងនិស្សិតអាហារូបករណ៍ដែលស្នាក់នៅក្នុងមណ្ឌលទាំងអស់ត្រូវដាក់អោយនៅដោយឡែកនៅក្នុងមណ្ឌលស្ដារនីតិសម្បទាទុំឪ ពួកគាត់អាចសិក្សាតាមប្រព័ន្ធអនឡាញ មិនអនុញ្ញាតិអោយចេញក្រៅទេ។ កុមារី និងបុគ្គលិកទាំងអស់ត្រូវអនុវត្តការរក្សាកម្លាតសង្គម និងការរក្សាអនាម័យខ្ពស់ ដូចជា ត្រូវពាក់ម៉ាស់មុខ លាងសំអាតដៃដេលអាល់កុលសម្លាប់មេរោគអោយបានញឹកញាប់បំផុតតាមតែអាចធ្វើបាននៅដែលពួកគេត្រូវចេញក្រៅដោយចាំបាច់។

ដើម្បីការពារការឆ្លងមេរោគកូវីដ-១៩ គ្រប់បុគ្គលិកទាំងអស់មិនអនុញ្ញាតិអោយចូលរួមព្រឹត្តិការណ៍សាធារណៈ ឬចេញទៅខាងក្រៅតាមទីសាធារណៈដែលមានហ្វូងមនុស្សអ៊ូអរច្រើនទេ ។ យើងបានផ្អាកភ្ញៀវមកសួរសុខទុក្ខនៅមណ្ឌលជាបណ្ដោះអាសន្ន ប៉ុន្តែក្នុងករណីចាំបាច់យើងអនុវត្តយ៉ាងតឹងរឹងបំផុតនូវគោលការណ៍អនាម័យ៣កុំនិង៣ការបាររបស់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

យើងបានធ្វើ និងចុះហត្ថលេខាលើអនុសារណៈនៃការយោគយល់គ្នា ស្ដីអំពីកម្មវិធីស្ដារនីតិសម្បទា អប់រំនិងបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ សមាហរណកម្មនិងតាមដានបន្តសំរាប់រយៈពេល៣ឆ្នាំ ពីខែកញ្ញាឆ្នាំ២០២១-កញ្ញាឆ្នាំ២០២៤ ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

យើងបានទទួលអំណោយបរិច្ចាករ៉ឺម៉កនិងម៉ូតូ(ទុក-ទុក)មួយគ្រឿងពីម្ចាស់គំរោងបុរីអោយភី(ក្រុមហ៊ុនអចលនទ្រព្យ)សំរាប់ជាមធ្យោបាយដឹកជញ្ជូនកុមារីប្រចាំថ្ងៃទៅសាលារៀនបឋមសិក្សាពីព្រោះថារ៉ឺម៉កមានស្រាប់វាមានអាយុកាលយូណាស់មកហើយ ចាស់ ពុកតួអស់ហើយមិនអាចប្រើបានតទៅទៀតទេ។

យើងបានរៀបចំតុបតែងលំអរបន្ទប់ផ្នែកចិត្តសាស្ត្រនៅក្នុងបន្ទប់ពិគ្រោះយោបល់និងក្នុងបន្ទប់សំរាប់ព្យាបាលបែបសិល្បៈ ដោយការរៀបចំដាក់ឈុតសាឡុងថ្មី គំនូរ ព្រំស៊្រីឪ ក្ដាខៀន នាឡិកាព្យួជញ្ជាំង ផ្ទាំងក្រណាត់រូបភាពព្យូជញ្ជាំង រៀបចំធ្នើដាក់សម្ភារ ធ្នើជញ្ជាំង រុក្ខជាតិតូចៗ ចំបូផ្កា ឈុតតុជ័រ ព្រំតូច កៅអីស្បោងពូក(bean bag)ព្រំផ្តុំរូបស្នោ ប្រដាប់សំអាតធូលី អំពូលភ្លើង ទៀនក្រអូប និងទូជ័រ។

ដោយស្ថានភាពធ្ងន់ធ្ងរនៃការរីករាលដាលមេរោគកូវីដ-១៩ បានឆ្លងដល់បុគ្គលិកចំនួន៥នាក់ និងយុវនារី-កុមារី កំពុងស្នាក់នៅក្នុងមណ្ឌលចំនួន១៥នាក់ នៅឆមាសទី២ឆ្នាំ២០២១ បានជំរុញអោយថ្នាក់ដឹកនាំពួកយើងសំរេចជាឯកច្ឆ័ន្ទ និងទទួលបានឯកភាពពីប្រធានក្រុមប្រឹក្សាពិបាល បានធ្វើអោយប្រសើរឡើងនូវបន្ទាប់ពេទ្យនៅក្នុងមណ្ឌល ដោយការបំពាក់ឧបករណ៍បំពង់អុកស៊ីសែន បរិក្ខាពេទ្យ សម្ភារពេទ្យផ្សេងៗ និងថ្នាំពេទ្យសំរាប់ការសង្គ្រោះបន្ទាន់ ដើម្បីយើងអាចផ្តល់សេវាកម្មថែទាំសុខភាពបន្ទាន់ដល់យុវនារី និងបុគ្គលិកនៅក្នុងមណ្ឌល។ លោកស្រីវេជ្ជបណ្ឌិត និងប្រធានមណ្ឌលជាគិលានុប្បដ្ឋាយិកា បានទទួលការបណ្ដុះបណ្ដាលអំពីការធ្វើការជាមួយអ្នកជម្ងឺកូវីដ-១៩ និងផ្តល់ការព្យាបាលដល់អ្នកជម្ងឺកូវីដ-១៩។

**អាគារថ្មី**-អាគារកំពស់៣ជាន់ មានរាងជាអក្សរអិល មានចំនួន៤១បន្ទប់ មាន៣ជាន់ គឺជាន់ផ្ទាល់ដី ជាន់ទី១ និងជាន់ទី២ មានទំហំប្រវែង៤៨ម៉ែត្រគុណនិង២៨ម៉ែត្រ ត្រូវបានសាងសង់រួចរាល់ដោយជោគជ័យនៅត្រីមាសទី១ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋាភិបាលបានចំណាយលើការជួលភូមិគ្រឹះអោយកុមារីស្នាក់នៅបណ្តោះអាសន្នរហូតដល់អាគារថ្មីបានកសាងរួចរាល់។ ស្ថាបនិកនិងនាយិកាគ្រប់គ្រងរបស់យើង លោកស្រីសុម៉ា លីម៉ម បានផ្ទេរកម្មសិទ្ធិដីមណ្ឌលទុំឌី ពីឈ្មោះលោកស្រីទៅអង្គការឈ្មោះមណ្ឌលទុំឌីវិញ។ សំណង់អាគារបានចាប់ផ្តើមសាងសងនៅខែមេសាឆ្នាំ២០១៩ ហើយបានរួចរាល់ជាស្ថាពរនៅត្រីមាសទី១ឆ្នាំ២០២១។ យើងបានអោយកុមារីនិងបុគ្គលិករើអីវ៉ាន់ចូលទៅរស់ក្នុងអាគារថ្មីនៅត្រីមាសទី១ឆ្នាំ២០២១។ យើងបានឈប់ជួលការិយាល័យសំរាប់បុគ្គលិកនិងកន្លែងស្នាក់សំរាប់និស្សិតអាហាររូបករណ៍នៅក្នុងក្រុង បានរើសម្ភារមកធ្វើការនៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌីវិញ ហើយនិស្សិតអាហាររូបករណ៍ចំនួន៦នាក់ និងយុវនារីហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅចំនួន១នាក់បានរើចូលមកស្នាក់ក្នុងមណ្ឌលទុំឌីតាំងពីអាគារថ្មីបានកសាងរួចរាល់នៅត្រីមាសទី១ឆ្នាំ២០២១មកម្លេះ។

**ការិយាល័យបុគ្គលិក**-អាគារថ្មី១ខ្នងបានសាងសងដាច់ដោយឡែកពីអាគារធំ មាន៤បន្ទប់ សំរាប់ការិយា ល័យបុគ្គលិកមាន៣បន្ទប់ និងបន្ទប់ប្រជុំ១បន្ទប់។

**ធ្វើរបងការពារអោយខ្ពស់ជាងមុននិងតម្លើងទ្វាររូត**-យើងធ្វើរបងខ្ពស់ជាងមុនដោយបន្ថែមលួសបន្លាពីលើរបងដែលមានស្រាប់កម្ពស់០.៥ម៉ែត្រចំនួន២២០ម៉ែត្រការ៉េបន្ថែមទៀត និងដាក់ទ្វាររូតចំនួន៣ផ្ទាំង (នៅអាគារការិយា ល័យ) ដើម្បីពង្រឹងសុវត្ថិភាពនិងសន្តិសុខដល់កុមារីរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌល បុគ្គលិកធ្វើការនៅមណ្ឌល និងការពារទ្រព្យសម្បត្តិអង្គការ។

**បំពាក់អំពូលថាមពលពន្លឺព្រះអាទិត្យខាងក្នុងជុំវិញបរិវេណមណ្ឌល**-ដើម្បីធានាបាននូវបរិយាកាសសុខសុវត្ថិភាពក្នុងបរិវេណមណ្ឌលដល់កុមារីរងគ្រោះ និងកាត់បន្ថយចំណាយលើការប្រើប្រាស់ថាមពលអគ្គិសនីនាពេលអនាគត យើងបានតម្លើងអំពូលថាមពលពន្លឺព្រះអាទិត្យសរុបចំនួន១៤អំពូល ដែលមានកំលាំងថាមពល៥០០វ៉ាត់ចំនួន៧អំពូល និងកំលាំងថាមពល២០០វ៉ាត់ចំនួន៧អំពូលនៅជុំវិញបរិវេណមណ្ឌលខាងក្នុង ដើម្បីជាជំនួយដល់បុគ្គលិកសន្តិសុខពេលយប់អាចមើលឃើញបានឆ្ងាយ ផ្តល់អារម្មណ៍សុវត្ថិភាពអំពីសន្តិសុខផ្ទាល់ខ្លួនប្រសើរជាងមុន។

**តម្លើងកាមេរ៉ាសុវត្ថិភាព**-យើងបានតម្លើងកាមេរ៉ាសុវត្ថិភាពនៅច្រកទ្វារធំចូលមណ្ឌល ចំណុចទាំង៣ជ្រុងនៅជាន់ទី២ ចំណុចទាំង៣ជ្រុងនៅជាន់ទី៣ ទីធ្លាសួនច្បារ ចំណុចទាំង៤ជ្រុងនៅជុំវិញមណ្ឌលនិងផ្ទះបាយ។ សរុបយើងបានតម្លើងកាមេរ៉ាសុវត្ថិភាពចំនួន២៥គ្រប់។

**ធ្វើស្នូលហាលសំលៀកបំពាក់**-យើងបានធ្វើស្នូលហាលសំលៀកបំពាក់ចំនួន១៦ស្នូលអោយកុមារីហាលសំលៀកបំពាក់ ក្នុង១បន្ទប់ស្នូល១ដាក់នៅរានហាលខាងក្រោយបន្ទប់គេងនីមួយៗ។

**បំពាក់វាំងននិងសំណាញ់ដែកតាមបង្អួច**-ដើម្បីអោយពន្លឺព្រះអាទិត្យជះចូលមកក្នុងបន្ទប់អោយបានគ្រប់គ្រាន់ យើងបានធ្វើទ្វារនិងបង្អួចទាំងអស់ពីកញ្ចក់ ក្នុគោលបំណងសន្សំសំចៃកាត់បន្ថយតម្លៃនៃការប្រើប្រាស់ថាមពលអគ្គិសនី។ នៅតាមបន្ទប់នីមួយ ៗ មានទ្វារកញ្ចក់២ បង្អួចកញ្ចក់២ នៅខាងមុខនិងខាងក្រោយ និងមានរានហាលខាងក្រោយបន្ទប់១។ នៅតាមបន្ទប់នីមួយ ៗ មានពំពាក់កង្ហាល់ធំជាប់ពិដាន១ តែមិនផ្តល់ខ្យល់ត្រជាក់គ្រប់គ្រាន់សំរាប់កុមារីគេង និងសិក្សាសកម្មភាពផ្សេងៗទេ នៅប្រទេសកម្ពុជាឧស្សាហ៍ដាច់ភ្លើងជាញឹកញាប់ជា

ពិសេសនៅតាមតំបន់ជាយក្រុង។ នៅពេលដាច់ភ្លើងម្តងៗកុមារីតែងតែបើកទ្វារបង្អួចដើម្បីអោយមានខ្យល់ចូលក្នុងបន្ទប់គេងនិងថ្នាក់រៀន ប៉ុន្តែរាល់ពេលបើកទ្វារបង្អួចមូសក៏ចូលមកខាំក្មេង ៗ ដែលរំខានដល់ការរៀនសូត្រនៅតាមថ្នាក់ ជាពិសេសនៅពេលយប់រំខានក្មេង ៗ គេងមិនបានគ្រប់គ្រាន់ ហើយនៅពេលមូសខាំជះឥទ្ធិពលអាក្រក់ដល់សុខភាពក្មេង ៗ ដូចជាជម្ងឺគ្រុនឈាមជាដើម។ ដូច្នេះដើម្បីការពារជម្ងឺគ្រុនឈាម និងជម្ងឺផ្សេង ៗ ចំពោះក្មេង ៗ ដែលយើងធ្វើការជាមួយបណ្តាលមកពីមូសខាំ យើបានបំពាក់សំណាញ់ដែកការពារមូសនៅតាមបង្អួចចំនួន២៩បង្អួចដែលក្មេង ៗ អាចបើកបង្អួចអោយខ្យល់ចេញចូលបានគ្រប់ពេលនៅពេលភ្លើងដាច់ម្តង ៗ ដោយមិនខ្លាចសត្វមូសទៀតទេ ព្រោះថាសំណាញ់ដែកអាចការពារពួកគេបាន។ យើងក៏បានបំពាក់វាំងននក្រណាត់ចំនួន៦៦បង្អួច និងទ្វារនៅតាមបន្ទប់គេង និងថ្នាក់រៀន ដើម្បីការពារបន្លឺព្រះអាទិត្យនៅពេលចាំបាច់ និងការពារឯកជនភាពរបស់ក្មេងស្រីនៅតាមបន្ទប់ ដូចជាការគេង និងផ្លាស់សំលៀកបំពាក់ជាដើម។ល។

**ធ្វើសួនច្បារ**-យើងបានធ្វើសួនច្បារនៅក្នុងបរិវេណមណ្ឌលដោយការដាំផ្កាផ្សេង ៗ តែដោយសារបញ្ហាលិចទឹកនៅពេលភ្លៀងម្តង ៗ ធ្វើអោយងាប់ផ្កាដែលបានដាំជាច្រើន ក្រុមហ៊ុនសម្រស់ធម្មជាតិបានឧបត្ថម្ភថវិកាកែលំអរសួនច្បារសារជាថ្មីដោយការចាក់ដីក្នុងសួនអោយខ្ពស់ជាងមុន ធ្វើអាសនៈអំពីបេតុងសំរាប់តម្កល់រូបបដិមាករ ដាំស្មៅក្នុងសួន ផ្កាផ្សេង ៗ បន្ថែម និងដាក់អំពូលភ្លើងប្រើថាមពលពន្លឺព្រះអាទិត្យសំរាប់បំភ្លឺនៅពេលយប់តាមសួន។

**ធ្វើចំណតរថយន្ត**-យើងបានធ្វើរោងសំរាប់ចតរថយន្ត ទោចក្រយានយន្ត ត្រីចក្រយានយន្ត ទោចក្រយានរបស់អង្គការ និងមធ្យោបាយធ្វើដំណើរផ្សេង ៗ របស់បុគ្គលិកក្នុងម៉ោងការងារ។

## ៣.៤ កម្មវិធីស្តារនីតិសម្បទា

យុវនារី-កុមារីចំនួន៩០នាក់ មកពីតាមបណ្តាខេត្ត-ក្រុង បានទទួលរបបអាហារប្រចាំថ្ងៃ ក្នុង១ថ្ងៃ៣ពេល សរុបចំនួន៧៤,៦៧៦ពេល និងបង្អែមផ្លែឈើស្រស់ប្រចាំសប្តាហ៍ចំនួន២ដងក្នុង១សប្តាហ៍ តួលេខនេះមិនរាប់បញ្ចូលរបបអាហារបង្អែមផ្លែឈើដែលបណ្តាសប្បុរសជននានាបានរៀបចំផ្តល់អោយយុវនារី-កុមារីទេ បានទទួលជំរកសុវត្ថិភាព និង សេវាកម្មការស្តារនីតិសម្បទាផ្សេង ៗ ទៀតនៅក្នុងមណ្ឌលស្តារនីតិសម្បទា ទុំឌី ។ ក្នុងនោះមានកុមារីចំនួន៦៣នាក់ នៅសល់ពីចុងខែធ្នូ ឆ្នាំ២០២០ កុមារីចំនួន៤នាក់បានទទួលចូលមណ្ឌលជាលើកទី២ដោយមូលហេតុហានិភ័យផ្សេងៗ និងកុមារីចំនួន២៣នាក់ផ្សេងទៀត ជាកុមារីចូលថ្មីនៅក្នុងមណ្ឌល ទុំឌី នៅក្នុងឆ្នាំ២០២១។ កុមារីចំនួន១៨នាក់បានបញ្ជូនចេញពីមណ្ឌល ហើយកុមារីចំនួន៧២នាក់ទៀតកំពុងបន្តស្នាក់នៅក្រោមការថែទាំក្នុងមណ្ឌល ទុំ ឌីបន្តទៅឆ្នាំ២០២២។

មានភ្ញៀវមកមណ្ឌលចំនួន៦០៤នាក់។ ក្នុងនោះបរទេសចំនួន២នាក់ ជនជាតិកម្ពុជាចំនួន៥៦២នាក់ និងសមាជិកក្រុមគ្រួសាររបស់កុមារីចំនួន៤០នាក់។

**តារាងស្ថិតិប្រចាំខែ និងអាយុរបស់យុវនារី-កុមារីដែលបានទទួលការថែទាំនៅមណ្ឌលទុំឌី បង្ហាញក្នុងតារាងខាងក្រោម**

| តារាងស្ថិតិប្រចាំខែរបស់កុមារីដែលបានទទួលការថែទាំនៅមណ្ឌល ទុំឌី | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **មករា** | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ៦៥ | ៦២ | ៦៤ | ៦៤ | ៦៦ | ៧០ | ៧០ | ៧០ | ៧២ | ៦៨ | ៧៤ | ៧២ |

| តារាងបង្ហាញពីប្រភេទបញ្ហាករណី និង អាយុរបស់កុមារីដែលបានទទួលការស្នាក់នៅ ថែទាំនៅមណ្ឌល ទុំឌី | |
|---|---|
| ប្រវត្តិជួញដូរ ឬ ប្រភេទបញ្ហាករណី | កម្រិតអាយុ |
| ៧៨នាក់ រង្គ្រោះដោយការរំលោភសេពសន្ថវៈ | ៦២នាក់ មានអាយុក្រោម១៦ឆ្នាំ |
| ៩នាក់ ករណីការពារបង្ការ (ហានិភ័យ) | ១៩នាក់ មានអាយុពី១៦-១៨ឆ្នាំ |
| ៣នាក់ រង្គ្រោះដោយការជួញដូរ | ៩នាក់ មានអាយុពី១៩-២៥ឆ្នាំ |

**រាជរដ្ឋាភិបាលកម្ពុជាបន្តឧបត្ថម្ភ**

- រដ្ឋាភិបាលបន្តចេញថ្លៃជួលផ្ទះ (ចេញដោយម្ចាស់គំរោងបុរីអាយភី) អោយកុមារីស្នាក់នៅរហូតដល់អាគារថ្មីបានសាងសង់រួច ហើយបានរើចូលទៅនៅជាស្ថាពរ។
- បានបន្តឧបត្ថម្ភអង្ករប្រចាំខែចំនួន១២០០គីឡូក្រាមក្នុង១ខែ។
- បន្តឧបត្ថម្ភថវិកាប្រចាំខែ១នាក់ចំនួន១០០,០០០.០០រៀលសំរាប់យុវនារី-កុមារីចំនួន១១៩នាក់
- អាគារថ្មី១ខ្នងកម្ពស់៣ជាន់មាន៤១បន្ទប់ និងអាគារការិយល័យ១ខ្នងមាន៤បន្ទប់ បានសាងសង់រួចរាលនៅខែមិនា ឆ្នាំ២០២១។
- រាជរដ្ឋាភិបាលកម្ពុជា បានឧត្ថម្ភថ្លៃម្ហូបប្រចាំខែក្នុង១ខែចំនួន១០,០០០,០០០.០០រៀល
- កាកបាតក្រហមកម្ពុជា បានឧបត្ថម្ភប្រចាំឆ្នាំក្នុង១ឆ្នាំចំនួន៣០,០០០,០០០.០០រៀល

**៣.៤.១ សុខភាព**-យុវនារី-កុមារីចូលថ្មីចំនួន២៧នាក់ បានទទួលការពិនិត្យសុខភាពទូទៅនៅពេលមកដល់មណ្ឌលភ្លាម។ យុវនារី-កុមារីចំនួន១១២នាក់ បានទទួលការពិនិត្យ តាមដាន និង ព្យាបាលសុខភាព តាមតម្រូវការជាក់ស្តែងនៃករណីនីមួយៗចំនួន១ ២៦៥ដង។ យុវនារី-កុមារីចំនួន៧៧នាក់បានទទួលការចាក់វ៉ាក់សាំងជាតិនៃវ៉ាក់សាំង១១មុខ យុវនារី-កុមារីចំនួន១៣៣នាក់បានទទួលការចាក់វ៉ាក់សាំងការពារវីរុសកូវីដ១៩ យុវនារី-កុមារីចំនួន៣៦នាក់បានទទួលការចាក់វ៉ាក់សាំងការពារជម្ងឺតេតាណុស យុវនារី-កុមារីចំនួន៣នាក់បានទទួលការចាក់វ៉ាក់សាំងការពារជម្ងឺថ្លើមប្រភេទបេ យុវនារី-កុមារីចំនួន៥នាក់បានទទួលការចាក់វ៉ាក់សាំងការពារជម្ងឺរលាកខួរក្បាល យុវនារី-កុមារីស្នាក់មណ្ឌលទុំឌីចំនួន៥៦នាក់បានទទួលការព្យាបាលនិងថែទាំសុខភាពមាត់ធ្មេញ និងយុវនារី-កុមារីចំនួន៦នាក់បានចូលសំរាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យ។

**៣.៤.២ សុខភាពផ្លូវចិត្ត( ចិត្តសាស្ត្រ)**-យុវនារី-កុមារីចំនួន១១១នាក់ បានទទួលការពិគ្រោះយោបល់ចិត្តសាស្ត្រ ការតាមដានបន្ត និង ការព្យាបាលតាមបែបចិត្តវិទ្យាចំនួន២៦៣ដង(វគ្គ)។ យុវនារី-កុមារីចំនួន៧២នាក់បានទទួលការព្យាបាលតាមបែបសកម្មភាពសិល្បៈចំនួន១៥ដង(វគ្គ) យុវនារី-កុមារីចំនួន៥៥នាក់បានទទួលការបណ្តុះបណ្តាលតាមរយៈក្រុមជួយខ្លួនឯងអំពីប្រធានបទផ្សេងៗចំនួន២២ដង(វគ្គ) យុវនារី-កុមារីចំនួន៧១នាក់បានទទួលការបណ្តុះបណ្តាលមូលដ្ឋាននៃការថែទាំសុខភាពផ្លូវចិត្តនិងការការពារបង្ការចំនួន១២ដង(វគ្គ) និងយុវនារី-កុមារីចំនួន៧៧នាក់បានទទួលការហ្វឹកហ្វឺនយោគៈនៅចុងសប្តាហ៍ចំនួន៥៥ដង(វគ្គ)នៅក្នុងមណ្ឌលទុំឌី។

**៣.៤.៣ គាំពារនីតិកម្ម**-កុមារីចំនួន៣៨នាក់ដែលពាក់ព័ន្ធផ្លូវច្បាប់បានទទួលជំនួយផ្នែកច្បាប់តាមនីតិវិធីច្បាប់នៅតុលាការ។ កុមារីចំនួន១៧នាក់ជាករណីចាស់សល់ពីចុងខែធ្នូ ឆ្នាំ២០២០ និង២១នាក់ទៀតជាករណីចូលថ្មីពាក់ព័ន្ធផ្លូវច្បាប់ ក្នុងឆ្នាំ២០២១។ ជនសង្ស័យចំនួន៣២នាក់ត្រូវបានចាប់ឃុំខ្លួនរងចាំសវនាកា ក្នុងនោះជនសង្ស័យចំនួន១៦

នាក់ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ២០២០និងជនសង្ស័យចំនួន១៦នាក់ទៀតត្រូវបានចាប់ខ្លួនក្នុងឆ្នាំ២០២១។ ជនល្មើសចំនួន៨នាក់ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារ កំរិតទោសជាប់ពន្ធនាគារទាបបំផុត៥ឆ្នាំ និងខ្ពស់បំផុត១៣ឆ្នាំ ។ សំណងរដ្ឋប្បវេណីទាបបំផុត៨លានរៀលនិងខ្ពស់បំផុត២០លានរៀល។

**៣.៥ កម្មវិធីអប់រំនិងហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ**

**៣.៥.១ ការអប់រំក្នុងប្រព័ន្ធខណៈពេលស្នាក់នៅមណ្ឌល**-យុវនារី-កុមារីចំនួន៦២នាក់បានទទួលការសិក្សាអប់រំក្នុងប្រព័ន្ធនៅសាលារដ្ឋខណៈកំពុងស្នាក់នៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី។ កុមរីចំនួន៥៦នាក់ ជាកុមារសល់ចាស់ពីចុងខែធ្នូឆ្នាំ២០២០ និង៦នាក់ទៀតជាកុមារីចូលថ្មីបានចូលរៀននៅក្នុងឆ្នាំ២០២១ ។ យុ

**៣.៥.២ ភាសាអង់គ្លេស កុំព្យូទ័រ និងបណ្ណាល័យ**-យុវនារី-កុមារីចំនួន៧៩នាក់ បានសិក្សាភាសាអង់គ្លេសនៅក្នុងមណ្ឌលទុំឌី ។ យុវនារី-កុមារីចំនួន៨៣នាក់ បានសិក្សាកុំព្យូទ័រនៅក្នុងមណ្ឌលទុំឌី។ យុវនារី-កុមារីចំនួន៦២នាក់បានចូលអានសៀវភៅផ្សេង ៗ នៅក្នុងបណ្ណាល័យនៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី។

**៣.៥.៣ អប់រំសហគមន៍-មាន**-យុវនារី-កុមារីចំនួន៥៨នាក់ បានទទួលការសិក្សាអប់រំសហគមន៍ ខណៈពេលពួកគាត់កំពុងរស់នៅជាមួយក្រុមគ្រួសារ ក្រោយពីពួកគាត់បានជាសះស្បើយ ពីជម្ងឺផ្លូវកាយ-ផ្លូវចិត្ត និង ទទួលបានការបញ្ជាក់អំពីសុវត្ថិភាពរបស់ពួកគាត់ថាអាចវិលត្រឡប់ទៅរស់នៅតាមសហគមន៍វិញបាន។ យើងបានធ្វើការតាមដានបន្តចំនួន១៨៨ដងជាមួយយុវនារី-កុមារីសិក្សាសហគមន៍។

**៣.៥.៤ អាហារូបករណ៍សកលវិទ្យាល័យ**-និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន១២នាក់បានទទួលការសិក្សាថ្នាក់ឧត្តមសិក្សានៅតាមបណ្តាសកលវិទ្យាល័យនានានៅរាជធានីភ្នំពេញ។ ក្នុងនោះមាននិស្សិតចំនួន៩នាក់សល់នៅចុងឆ្នាំ២០២០ និង៣នាក់ទៀតជានិស្សិតថ្មីក្នុងឆ្នាំ២០២១ ។ និស្សិតអាហារូបករណ៍ចំនួន១១នាក់បានទទួលការឧបត្ថម្ភថ្លៃសាលា ថ្លៃសិក្សា ការរស់នៅប្រចាំខែ ការតាមដានបន្តនិងថែទាំសុខភាព។ យើងបានធ្វើការតាមដានបន្តជាទៀងទាត់ជាមួយនិស្សិតទាំង១២នាក់បានចំនួន១៤៤ដង ការតាមដានបន្តយើងផ្តោតលើវឌ្ឍនភាពនៃការសិក្សា បញ្ហាប្រឈម ស្ថានភាពសុខភាពផ្លូវកាយ និងផ្លូវចិត្ត ។

**៣.៥.៥ ហ្វឹកហ្វឺនជំវិជ្ជាជីវៈខាងក្រៅ**-យុវនារីចំនួន១៥នាក់បានទទួលការឧបត្ថម្ភការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈនៅខាងក្រៅ និងការឧបត្ថម្ភការរស់នៅប្រចាំខែ ។ ក្នុងនោះមានយុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅចំនួន៤នាក់សល់ពីចុងឆ្នាំ២០២០ និង១១នាក់ទៀតជាយុវនារីទទួលការហ្វឹកហ្វឺនជំនាញចូលថ្មីក្នុងឆ្នាំ២០២១។ យុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅទាំង១៥នាក់ទទួលបានការឃ្លាំមើលនិងតាមដានបន្តចំនួន៨១ដង ។ យ៉ាងហោចណាស់យើងធ្វើការតាមដានបន្តប្រចាំខែ១ដងជាមួយយុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅ១នាក់។ ការតាមដានបន្តយើងធ្វើតាមរយៈការចុះជួបផ្ទាល់ និងតាមទូរស័ព្ទតាមស្ថានភាពជាក់ស្តែង ដោយផ្តោតលើវឌ្ឍនភាពនៃការសិក្សាជំនាញ បញ្ហាប្រឈម ការរស់នៅ និងសុខភាព។

**៣.៦ កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច**-យុវនារី-កុមារីចំនួន២២នាក់បានទៅលេងគ្រួសារចំនួន២៧ដង អនុវត្តការទៅលេងគ្រួសារបានតិចដោយសារបញ្ហាការរីករាលដាលមេរោគកូវីដ១៩។ គ្រួសារកុមារីចំនួន២គ្រួសារបានទទួលការ

ឧបត្ថម្ភគ្រួសារដើម្បីពង្រីកមុខរបរនិងសាងសង់ផ្ទះ។ យុវនារីសមាហរណកម្មចំនួន៥នាក់បានទទួលការឧបត្ថម្ភបន្ថែមក្រោយសមាហរណកម្មសំរាប់ការថែទាំសុខភាពនិងអាហារ។ យុវនារីចំនួន៤នាក់ បានធ្វើសមាហរណកម្មដោយឧបត្ថម្ភការងារ ។ យុវនារីសមាហរណកម្មដោយការឧបត្ថម្ភមុខរបរខ្នាតតូច និង ការងារ ចំនួន៥០នាក់បានទទួលការតាមដានបន្តចំនួន១៦៥ដងទាំងដោយការចុះផ្ទាល់និងតាមរយៈទូរស័ព្ទ។

**៣.៧ កម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ**-យុវនារីជាអតីតជនរងគ្រោះចំនួន២១នាក់ ត្រូវបានជ្រើសរើសអោយចូលជាសមាជិកកម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ(SEN) ប៉ុន្តែពួកគាត់មិនទាន់បានបំពេញទំរង់សមាជិកភាពនៅឡើយទេ ដោយសារបញ្ហាការរីករាលដាលនៃមេរោគកូវីដ១៩ យើងនឹងចាប់ផ្តើមបំពេញទំរង់បែបបទចូលជាសមាជិកនៅពេលការរីករាលដាលនៃមេរោគបានប្រសើរឡើង។ ក្នុងនោះសមាជិកចំនួន២០នាក់នៅភ្នំពេញនិង១នាក់ទៀតនៅខេត្តសៀមរាប។

ប្រធានកម្មវិធី SEN បានធ្វើការយ៉ាងជិតស្និតជាមួយបណ្តាកម្មវិធីពាក់ព័ន្ធផ្សេងៗ ដើម្បីជ្រើសរើសយុវនារី-កុមារីចំនួន១០៣នាក់ក្នុងចំណោមយុវនារី-កុមារីចំនួន១១៩នាក់ អោយទទួលប្រាក់ហោប៉ៅឧបត្ថម្ភប្រចាំខែពីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះមានចំនួន៦៦នាក់ជាយុវនារី-កុមារីកំពុងស្នាក់នៅក្នុងមណ្ឌល ២៥នាក់ជាយុវនារី-កុមារីសិក្សាសហគមន៍ ១២នាក់ជានិស្សិតអាហារូបករណ៍សកលវិទ្យាល័យ ។ ក្នុងយុវនារី-កុមារី១នាក់ទទួលបានប្រាក់ហោប៉ៅឧបត្ថម្ភប្រចាំខែ១០០,០០០.០០រៀល(២៥ដុល្លារអាមេរិក)ក្នុង១ខែ។ ១៦នាក់ទៀតយើងបម្រុងទុកសំរាប់ផ្តល់ជូនយុវនារី-កុមារីរងគ្រោះចូលថ្មីនៅមណ្ឌលស្តារនីតិសម្បទាទុំឌី។

**៣.៨ សមិទ្ធិផលសំរេចបាន**

តារាខាងឆ្វេង នៅខាងក្រោមនេះ គឺជាសុច្ចនៈកររំពឹងទុក ដែលយើងបានចងក្រងឡើងជាមួយបណ្តាប្រធានកម្មវិធី នៅក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ប្រចាំឆ្នាំដែលបានប្រព្រឹត្តទៅ នៅមណ្ឌលស្តារនីតិសម្បទាទុំឌី នៅរាជធានីភ្នំពេញនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ហើយតារាងខាងស្តាំគឺបង្ហាញអំពីសមិទ្ធិផលសំរេចបាននូវសុច្ចនៈរំពឹងទុកនីមួយ ៗ ឬផែនការដែលបុគ្គលិកកម្មវិធីនីមួយ ៗ អនុវត្តបានសំរាប់រយៈពេល១២ខែកន្លងទៅនេះ។

| **សុច្ចនៈកររំពឹងទុក ឆ្នាំ២០២១** | **សមិទ្ធិផលសំរេចបាន ឆ្នាំ២០២១** |
|---|---|
| **៣.៨.១ កម្មវិធីស្តារនីតិសម្បទា** | |
| 3.8.1.1 យុវនារី-កុមារីចំនួន៨០នាក់ នឹងទទួលបានការស្តារនីតិសម្បទា នៅមណ្ឌលទុំឌី។ ក្នុងនោះយុវនារី-កុមារីចំនួន៥៥នាក់ សល់ពីចុងឆ្នាំ២០២០ ហើយ២៥នាក់ទៀតជាយុវនារី-កុមារីចូលថ្មីក្នុងឆ្នាំ២០២១។ | 3.8.1.1 យុវនារី-កុមារី ចំនួន៩០នាក់ បានទទួលសេវាកម្មស្តារនីតិសម្បទា នៅមណ្ឌលទុំឌី។ ក្នុងនោះ ៦៣នាក់ ជាយុវនារី-កុមារីសល់ពីចុងខែធ្នូ ឆ្នាំ២០២០ និង ២៧នាក់ (៤នាក់ចូលមណ្ឌលវិញ) ទៀតជាយុវនារី-កុមារីចូលថ្មីក្នុឆ្នាំ២០២១ ។<br>***កំណត់ចំណាំ:***ស្ថិតិនេះនេះមិនរាប់បញ្ចូលនិស្សិតអាហារូបករណ៍ចំនួន៦នាក់និងយុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅចំនួន១នាក់បានស្នាក់ណនៅក្នុង |

| | |
|---|---|
| | មណ្ឌលទេ។<br><br>យុវនារី-កុមារីចំនួន១៨នាក់ ក្នុងចំណោម៩០នាក់ បានបញ្ជូនចេញពីមណ្ឌល ហើយមានយុវនារី និង កុមារីចំនួន៧២នាក់កំពុងបន្តស្នាក់នៅ និងទទួលការថែទាំនៅក្នុងមណ្ឌលទុំឌី បន្តទៅឆ្នាំ២០២២:<br><br>- ៧នាក់ចេញទៅហ្វឹកហ្វឺនជំនាញខាងក្រៅ<br>- ១នាក់(ប្រឡងជាប់)ទៅរៀននៅសកលវិទ្យាល័យ<br>- ៨នាក់បញ្ជូនទៅគ្រួសារអប់រំសហគមន៍<br>- ២នាក់សមហរណកម្មទៅគ្រួសារនៅសហគមន៍ |
| 3.8.1.2 យើងនឹងជួលគ្រូបង្រៀនរបាំប្រពៃណីខ្មែរពាក់កណ្ដាលពេលចំនួន២នាក់ ដើម្បីបង្ហាត់របាំប្រពៃណីខ្មែរ យុវានរី-កុមារី នៅមណ្ឌលទុំឌី។ | 3.8.1.2 យើងមិនបានជួលគ្រូបង្រៀនរបាំប្រពៃណីខ្មែរទេ ដោយសារបញ្ហារីករាលដាលនៃជម្ងឺកូវីដ១៩ យើងបានផ្អាកសកម្មភាពនេះ ។ |
| 3.8.1.3 យើងនឹងរៀបចំការកំសាន្តសប្បាយផ្សេងៗចំនួន៤ដង អោយយុវនារី-កុមារី ដែលស្ថិតនៅក្រោមការថែទាំនៅមណ្ឌលទុំឌី អោយបានទទួលការកំសាន្តសប្បាយ និង សំរាក់លំហែរ ដូចជា បុណ្យចូលឆ្នាំប្រពៃណីខ្មែរ ទិវាសិទ្ធិកុមារអន្តរជាតិ បុណ្យភ្ជុំបិណ្ឌនិងការប្រារព្ធពិធីឆ្លងឆ្នាំសកល ជាដើម។ | 3.8.1.3 យើងបានប្រារព្ធការកំសាន្តសប្បាយចំនួន៤ដងសំរាប់យុវនារី-កុមារី គឺពីធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ និងទិវាសិទ្ធិកុមារអន្តរជាតិនៅក្នុងមណ្ឌលទុំឌី ដំណើរដំណើរកំសាន្តបោះតង់នៅឌីវ៉ាល់ខេត្តកំពង់ស្ពឺ ឆ្លងឆ្នាំសកលនៅក្នុងមណ្ឌល ដែលឧបត្ថម្ភដោយក្រុមហ៊ុនសម្រស់ធម្មជាតិ ប៉ុន្តែយើងមិនបានប្រារព្ធបុណ្យភ្ជុំបិណ្ឌទេដោយសារនៅក្នុងខែកញ្ញានិងតុលាមានបុគ្គលិក និងយុវនារី-កុមារីឆ្លងមេរោគកូវីដ-១៩។ |
| 3.8.1.4 យើងនឹងកសាងទំនាក់ទំនងល្អ និង បញ្ជ្រៀប ការយល់ដឹង អំពីសកម្មភាពការងារអង្គការអាហ្វេស៊ីបកម្ពុជា ដល់បណ្ដាអ្នកគាំទ្រ និង អង្គការដៃគូរ។ | 3.8.1.4 មានភ្ញៀវចំនួន៦០៤នាក់ បានធ្វើទស្សនៈកិច្ចនៅមណ្ឌលទុំឌី ដើម្បីសិក្សាស្វែងយល់ អំពីសកម្មភាពការងារ អង្គការ អាហ្វេស៊ីប-កម្ពុជា។ ក្នុងនោះមានភ្ញៀវចំនួន២នាក់ជាជនបរទេស ភ្ញៀវចំនួន៥៦២នាក់ជានជនជាតិកម្ពុជនិង ភ្ញៀវចំនួន៤០នាក់ទៀតជាសាច់ញាតិរបស់យុវនារី-កុមារី។ ភ្ញៀវមួយចំនួនបានផ្ដល់ម្ហូបអាហារ |

| | |
|---|---|
| | សម្ភារៈសិក្សា សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ។<br><br>យើងបានចូលរួមប្រជុំជាច្រើន ភាគច្រើនគឺប្រជុំតាមអនឡាញ:<br><br>- បានចូលរួមប្រជុំនៅសណ្ឋាគារសូហ្វីតែល ដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ ស្តីពីផែនការណ៍ជាតិ៥ឆ្នាំក្នុងការការពារអំពើហឹង្សាលើស្ត្រី ក្រោមអធិបតីភាពឧបនាយករដ្ឋមន្ត្រី **សរ ខេង**។<br><br>- ការប្រជុំតាមប្រព័ន្ធអនឡាញជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃក្រសួងសង្គមកិច្ចស្តីពីពង្រៀងអនុសារណៈនៃការយោគយល់គ្នារវាងអង្គការអាហ្វេស៊ីប-កម្ពុជា និងក្រសួងសង្គាមកិច្ច។<br><br>- ការប្រជុំតាមប្រព័ន្ធអនឡាញរៀបចំដោយមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ស្តីពីបច្ចុប្បន្នភាពមណ្ឌលអង្គការក្រៅរដ្ឋាភិបាល និងផលប៉ះពាល់នៃការរាតត្បាតមេរោគកូវីដ-១៩។<br><br>- ការប្រជុំតាមប្រព័ន្ធអនឡាញជាមួយក្រុមការងារធនាគារប្រែសនីយស្តីពីសក្កានុពលនៃការផ្តល់ជំនួយ។ យើងបានធ្វើបទបង្ហាញផ្ទាល់មាត់អំពីកម្មវិធីស្នូលទាំង៤ បានអញ្ជើញក្រុមការងារធនាគារប្រែសនីយអោយចូលមើលគេហទំព័ររបស់អង្គការអាហ្វេស៊ីប និងផ្តល់ជូននូវតម្រូវការឯកសារចាំបាច់ផ្សេង ៗ ដើម្បីដាក់ជូនប្រធាន(អគ្គ)នាយកធនាគារពិនិត្យពិចារណាក្នុងការផ្តល់ការបរិច្ចាកជំនួយដល់អង្គការអាហ្វេស៊ីប-កម្ពុជា។<br><br>- ការប្រជុំបុគ្គលិកប្រចាំខែនិងប្រចាំសប្តាហ៍បានរៀបចំឡើងជាទៀងទាត់ទាំងការប្រជុំផ្ទាល់និងការប្រជុំតាមប្រព័ន្ធអនឡាញ។ |
| **ការពិនិត្យ និង ព្យាបាលសុខភាព** | |

| | | | |
|---|---|---|---|
| 3.8.1.5 | យុវនារី-កុមារីចូលថ្មីនៅមណ្ឌល ទុំឌី ចំនួន ២៥នាក់ នឹងទទួលបាន ការថែទាំ ពិនិត្យ និង ព្យាបាលសុខភាពនៅពេលមកដល់មណ្ឌល។ | 3.8.1.5 | ១០០%ក្នុងចំណោមយុវនារី-កុមារីចូលថ្មីទាំងអស់ចំនួន២៧នាក់ នៅមណ្ឌល ទុំឌី បានទទួលការពិនិត្យ និង ព្យាបាលសុខភាពទូទៅ នៅពេលពួកគាត់ចូលមកដល់មណ្ឌល។ រោគសញ្ញាសំខាន់ៗចំនួន៥នៃសុខភាពផ្លូវកាយរបស់យុវនារី-កុមារី គឺឈឺពោះ រលាកមាត់ស្បូន ប៉ារ៉ាស៊ីត ប៉ាក់តេរីទ្វាមាស និងកាមរោគ។ |
| 3.8.1.6 | យុវនារី-កុមារីចំនួន៨០នាក់នឹងទទួលបានការតាមដាន ការពិនិត្យ និងព្យាបាលសុខភាព នៅក្នុងមណ្ឌល និងនៅតាមមន្ទីរពេទ្យខាងក្រៅតាមតម្រូវការជាក់ស្តែង។ | 3.8.1.6 | យើងបានផ្តល់ការពិនិត្យតាមដាន ការថែទាំ និងព្យាបាលសុខភាពដល់យុវនារី-កុមារីចំនួន ១១២នាក់ តាមតម្រូវការជាក់ស្តែង នៃករណីនីមួយ ៗ (យុវនារី-កុមារីស្នាក់នៅក្នុងមណ្ឌល ហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈនៅខាងក្រៅ អាហារូបករណ៍សកលវិទ្យាល័យ អប់រំសហគមន៍ និងសមាហរណកម្ម)។ |
| 3.8.1.7 | យុវនារី-កុមារីចំនួន៨០នាក់នឹងទទួលបានការចាក់ វ៉ាក់សាំងជាតិនៃវ៉ាក់សាំង១១មុខ។ យុវនារី-កុមារីចំនួន៨០នាក់នឹងទទួលបានការចាក់វ៉ាក់សាំងការពារបង្ការជម្ងឺតេតាណូស។ យុវនារី-កុមារីចំនួន៨០នាក់នឹងទទួលបានការចាក់វ៉ាក់សាំងការពារបង្ការជម្ងឺថ្លើមប្រភេទបេ។ យុវនារី-កុមារីចំនួន១០៥នាក់នឹងទទួលបានការចាក់វ៉ាក់សាំងការពារបង្ការជម្ងឺគ្រុនឈាម និងយុវនារី-កុមារីចំនួន៩នាក់នឹងទទួលបានការចាក់វ៉ាក់សាំងការពារបង្ការជម្ងឺផ្សេងៗ។ | 3.8.1.7 | យុវនារី-កុមារីចំនួន៤៤នាក់បានទទួលការចាក់វ៉ាក់សាំងជាតិនៃវ៉ាក់សាំង១១មុខ។ យុវនារី-កុមារីចំនួន៣៦នាក់បានទទួលការចាក់សាំងការពារបង្ការជម្ងឺតេតាណូស។ យុវនារី-កុមារី៣នាក់បានទទួលការចាក់វ៉ាក់សាំងការពារបង្ការជម្ងឺថ្លើមប្រភេទបេ និងយុវនារី-កុមារី៥នាក់ផ្សេងទៀតបានទទួលការចាក់វ៉ាក់សាំងការពារបង្ការជម្ងឺរលាកខួរក្បាល។ យើងខកខានមិនបានផ្តល់ការចាក់វ៉ាក់សាំងការពារបង្ការជម្ងឺគ្រុនឈាម និងវ៉ាក់សាំងផ្សេងៗ ទៀតដល់យុវនារី-កុមារីទេ ដោយបញ្ហាថវិកាដែលមានផលប៉ះបាល់បណ្តាលមកពីការរាតត្បាតមេរោគ។ |
| 3.8.1.8 | យុវនារី-កុមារីនៅមណ្ឌលទុំឌីចំនួន៨០នាក់នឹងទទួលបានការពិនិត្យ ព្យាបាលសុខភាពមាត់ធ្មេញ ចំនួន៤ដង ជារៀងរាល់៣ខែម្តង ដោយសហការជាមួយមូលនិធិគ្រួសារពិភពលោកដោយមិនគិតថ្លៃសេវា យើងគ្រាន់តែចំណាយ លើមធ្យោបាយធ្វើដំណើរ អាហារ | 3.8.1.8 | យុវនារី-កុមារី ចំនួន៥៦នាក់បានទទួលការពិនិត្យ ព្យាបាល និង ការបណ្តុះបណ្តាលអំពីការថែទាំសុខភាពមាត់ធ្មេញ ចំនួន៦៩ដង(វគ្គ) សហការជាមួយមូលនិធិគ្រួសារពិភពលោក ដោយមិនគិតថ្លៃសេវា យើងគ្រាន់តែចំណាយលើមធ្យោបាយធ្វើដំណើរ អាហារពេលព្រឹក អាហារថ្ងៃត្រង់ និងភេសជ្ជៈផ្សេង ៗ ក្នុងអំឡុង |

| | | | |
|---|---|---|---|
| | ពេលព្រឹក អាហារថ្ងៃត្រង់ និងភេសជ្ជៈផ្សេងៗ ក្នុងអំឡុងពេលរងចាំ។ | | ពេលរងចាំ។ ថ្វីបើយើងមិនបានអនុវត្តគ្រប់តាមផែនការណ៍រំពឹងទុក ប៉ុន្តែយុវនារី-កុមារីទាំងដែលមានបញ្ហាសុខភាពមាត់ធ្មេញគឺបានទទួលការពិនិត្យព្យាបាលទាំងអស់ ។ |
| 3.8.1.9 | យើងនឹងផ្តល់ការពិនិត្យ និង ព្យាបាលសុខភាពភ្នែក (EENT) ដល់យុវនារី-កុមារីចំនួន ៤០នាក់ ដោយសហការជាមួយមជ្ឈមណ្ឌលវះកាត់កុមារី (Children Surgical Center) ដោយមិនគិតថ្លៃសេវា យើងគ្រាន់តែចំណាយលើមធ្យោបាយធ្វើដំណើរ អាហារពេលព្រឹក អាហារថ្ងៃត្រង់ និងភេសជ្ជៈផ្សេងៗ ក្នុងអំឡុងពេលរងចាំ។ | 3.8.1.9 | យុវនារី-កុមារីចំនួន៦២នាក់ បានទទួលការពិនិត្យ ព្យាបាលសុខភាពភ្នែក នៅមជ្ឈមណ្ឌលវះកាត់កុមារី (Children Surgical Center) ដោយមិនគិតថ្លៃសេវា យើងគ្រាន់តែចំណាយ លើមធ្យោបាយធ្វើដំណើរ អាហារពេលព្រឹក អាហារថ្ងៃត្រង់ និងភេសជ្ជៈផ្សេងៗ ក្នុងអំឡុងពេលរងចាំ។ |
| 3.8.1.10 | យើងនឹងផ្តល់ការពិនិត្យឈាមរកមេរោគ CBC, glycaemia, Ag_Anti-HBS ដល់យុវនារី-កុមារីចំនួន80នាក់ ។ | 3.8.1.10 | យុវនារី-កុមារីចំនួន១៥នាក់បានទទួលការពិនិត្យឈាមរកមេរោគ CBC, glycaemia, Ag_Anti-HBS ក្នុងឆ្នាំ២០២១។ លទ្ធផលសំរេចបានទាបជាងផែនការណ៍ដែលយើងបានរំពឹងទុកដោយសារផលប៉ះពាល់នៃការរាតត្បាតមេរោគកូវីដ១៩។ |
| 3.8.1.11 | យុវនារី-កុមារីចំនួន១០៥នាក់( ៨០នាក់ ជាយុវនារី-កុមារីស្នាក់នៅក្នុងមណ្ឌល ២៥នាក់ទៀត ជាអប់រំសហគមន៍ ហ្វឹកហ្វឺនជំនាញខាងក្រៅ និស្សិតអាហារូបករណ៍សកលវិទ្យាល័យ ) នឹងទទួលបានការចាក់វ៉ាក់សាំងការពារជម្ងឺផ្តាសាយ។ | 3.8.1.11 | យើងមិនបានអនុវត្តសកម្មភាពនេះទេដោយសាបញ្ហាការរាតត្បាតជម្ងឺកូវីដ-១៩។ |
| 3.8.1.12 | យុវនារី-កុមារីចំនួន១០៥នាក់( ៨០នាក់ ជាយុវនារី-កុមារីស្នាក់នៅក្នុងមណ្ឌល ២៥នាក់ទៀត ជាអប់រំសហគមន៍ ហ្វឹកហ្វឺនជំនាញខាងក្រៅ និស្សិតអាហារូបករណ៍សកលវិទ្យាល័យ ) នឹងទទួលបានការចាក់វ៉ាក់សាំងការពារបង្ការមេរោគកូវីដ-១៩។ | 3.8.1.12 | ១៥៩នាក់ បានទទួលការចាក់វ៉ាក់សាំងការពារបង្ការមេរោគកូវីដ-១៩ ក្នុងនោះមានយុវនារី-កុមារីស្នាក់នៅក្នុងមណ្ឌលចំនួន៦៥នាក់ ហ្វឹកហ្វឺនជំនាញខាងក្រៅចំនួន៨នាក់ អប់រំសហគមន៍ចំនួន៤៨នាក់ និស្សិតអាហារូបករណ៍ចំនួន១២នាក់បានទទួលចាក់វ៉ាក់សាំងដូសទី២ និងបុគ្គលិកចំនួន២៦នាក់បានទទួលចាក់វ៉ាក់សាំងដូសទី៣។ |

| | |
|---|---|
| 3.8.1.13 យើងនឹងផ្តល់ការពិនិត្យ ធ្វើតេស្តរកមេរោគមហារីកមាត់ស្បូនយុវនារី-កុមារីចំនួន៦០នាក់ និងចាក់ថ្នាំបង្ការជម្ងឺមហារីកមាត់ស្បូនដល់យុនារី-កុមារីចំនួន៦០នាក់ ។ | 3.8.1.13 យើងមិនបានអនុវត្តសកម្មភាពនេះទេដោយសារបញ្ហាថវិកា បណ្តាលមកពីផលប៉ះពាល់នៃការរាតត្បាតមេរោគកូវីដ-១៩។ |
| 3.8.1.14 យុវនារី-កុមារីចំនួន៨០នាក់នឹងទទួលបានការបណ្តុះបណ្តាលមូលដ្ឋាននៃការថែទាំសុខភាពចំនួន៥ដង(វគ្គ)ស្តីពីការលូតលាស់នៃសរីរាង្គ ការមានគភ៌ ការលូតលាស់របស់កុមារ ការលូតលាស់ពេញវ័យរបស់មនុស្សប្រុស និងការលូតលាស់ពេញវ័យរបស់មនុស្សស្រី។ | 3.8.1.14 យុវនារី-កុមារីចំនួន៦២នាក់បានទទួលការបណ្តុះបណ្តាលបំណិនជីវិតពីមូលដ្ឋាននៃការថែទាំសុខភាព ស្តីអំពីកូវីដ-១៩ ម៉ាស់ ការពារកម្មរស្មីយូវី ក្លរសំរាប់សំអាត ការលាយអាល់កុល។ ដោយការរាតត្បាតមេរោគកូវីដ-១៩ យើងមិនអាចផ្តល់វគ្គបណ្តុះបណ្តាលអោយបានច្រើនជាងនេះទេ ព្រោះយើងត្រូវអនុលោមតាមវិធានការក្រសួងសុខាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការការពារការឆ្លងមេរោគកូវីដ-១៩។ |
| 3.8.1.15 យុវនារី-កុមារីចំនួន៦នាក់នឹងទទួលបានការថែទាំបន្ទាន់និងការសំរាកព្យាបាលនៅមន្ទីរពេទ្យ។ | 3.8.1.15 យុវនារី-កុមារីចំនួន៦នាក់ បានទទួលការថែទាំបន្ទាន់និងចូលសំរាកព្យាបាលនៅតាមមន្ទីរពេទ្យចំនួន៨ដង នៅមន្ទីរពេទ្យកុមារជាតិ មន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត មន្ទីរពេទ្យគុន្ធបុប្ផា និងមន្ទីរពេទ្យបង្អែកខេត្តក្រចេះ ដោយមានរោគវិនិច្ឆ័យជម្ងឺ Systemic Lumpus Eryphematous, Ultrasound and PCR for hepatitis B, Plaie vaginal, Crete du Coq, repair vaginal and SLT។ ក្នុងនោះ៥នាក់ជាយុវនារី-កុមារីកំពុងស្នាក់នៅក្នុងមណ្ឌលហើយ ១នាក់ទៀតជាករណីយុវនារីសមាហរណកម្មដែលបានបិទហើយ។ ជាអកុសលករណីយុវនារីសមាហរណកម្មដែលបានបិទមានលេខកូដKC-០០២៨បានទទួលមរណៈភាពនៅក្នុងឆមាសទី២ដោយជម្ងឺប្រឆាំងប្រព័ន្ធរាង្គកាយ (SLE) ដែលធ្វើអោយខូចតម្រងពោមទាំង២។ |
| 3.8.1.16 យុវនារី-កុមារីចំនួន២នាក់នឹងទទួលបានថ្នាំសំរាប់ព្យាបាលជម្ងឺប្រចាំកាយ។ | 3.8.1.16 យុវនារី-កុមារីចំនួន៣នាក់ បានទទួលថ្នាំព្យាបាលជម្ងឺប្រចាំកាយ សំរាប់រោគវិនិច្ឆ័យលើជម្ងឺ |

| | |
|---|---|
| | កាមរោគ ( សេមាន់ ) ( Crete du coq), កាមរោគ ( Trichomonas ) និងរលាកមាត់ស្បូន។ |
| 3.8.1.17 នឹងផ្តល់ថ្នាំពេទ្យសំរាប់ព្យាបាលយុវនារី-កុមារីចំនួន៣នាក់ដែលមានជម្ងឺថ្លើមប្រភេទបេ។ | 3.8.1.17 យុវនារី-កុមារីចំនួន៣នាក់បានទទួលថ្នាំព្យាបាលជម្ងឺថ្លើមប្រភេទបេ។ |
| 3.8.1.18 ថតអេកូនិងធ្វើតេស្តដើម្បីធ្វើរោគវិនិច្ឆ័យ។ | 3.8.1.18 យុវនារី-កុមារីចំនួន៣នាក់បានថតអេកូនិងធ្វើតេស្តមើលមេរោគថ្លើម្បភេទបេ។ |
| 3.8.1.19 ទិញសម្ភារនិងឧបករណ៍ពេទ្យ។ | 3.8.1.19 យើងបានទិញថ្នាំពេទ្យ វីតាមីនស៊ី សម្ភារនិងបរិក្ខាពេទ្យសំរាប់បំរើអោយសកម្មភាពប្រចាំថ្ងៃរបស់កម្មវិធីសុខភាព ក្នុងការពិនិត្យព្យាបាលជម្ងឺអោយយុវនារី-កុមារីដែលជាអ្នកទទួលផលពីអង្គការអាហ្វេស៊ីបដែលកំពុងស្នាក់នៅក្នុងមណ្ឌលនិងនៅក្រៅមណ្ឌល។ |
| **សុខភាពផ្លូវចិត្ត ( ចិត្តសាស្ត្រ )** | |
| 3.8.1.20 យើងនឹងជ្រើសរើសបុគ្គលិកចិត្តសាស្ត្រស្ម័គ្រចិត្តចំនួន២នាក់អោយចូលបំរើការជួយដល់កម្មវិធីចិត្តសាស្ត្រក្នុងឆ្នាំ២០២១លើផ្នែកយោគៈ( ហ្វឹកហ្វឺនការសំរាក )និងសុខភាពផ្លូវចិត្តបឋម( ល្បែងថាមពល )សំរាប់រយៈពេលយ៉ាងតិច៣ខែ។ | 3.8.1.20 មិនបានអនុវត្តសកម្មភាពនៃការជ្រើសរើសបុគ្គលិកចិត្តសាស្ត្រស្ម័គ្រចិត្តចំនួន២នាក់អោយចូលបំរើការងារកម្មវិធីចិត្តសាស្ត្រទេ ដោយសារការរាតត្បាតមេរោគកូវីដ-១៩ យើងបានផ្អាកសកម្មភាពនេះជាបណ្តោះអាសន្នរហូតដល់ស្ថានភាពប្រសើរឡើង។ |
| 3.8.1.21 យើងនឹងធ្វើការវាយតម្លៃចិត្តសាស្ត្រ យុវនារី-កុមារីចូលថ្មី១០០% (២៥នៃ៨០នាក់) នៅពេលពួកគាត់ចូលមកដល់មណ្ឌល។ | 3.8.1.21 ១០០%នៃយុវនារី-កុមារីចូលថ្មីចំនួន២៧នាក់បានទទួលការវាយតម្លៃផ្នែកចិត្តសាស្ត្រ និងពិគ្រោះយោបល់ ចំនួន២៨ដង(វគ្គ)នៅពេលចូលមកដល់មណ្ឌល ទុំឌី។ រោគសញ្ញាសំខាន់ៗ ចំនួន៥ នៃសុខភាពផ្លូវចិត្ត គឺការថប់អារម្មណ៍ អារម្មណ៍មិនសប្បាយចិត្ត នឹកផ្ទះ សម្រក់ទឹកភ្នែក និងព្រួយបារម្ភ។ |
| 3.8.1.22 យុវនារី-កុមារី៨០នាក់(២៥ចូលថ្មី) ដែលត្រូវការការពិគ្រោះយោបល់ចិត្តសាស្ត្រ នឹងទទួលបានការតាមដានបន្តនៃការពិគ្រោះ | 3.8.1.22 យុវនារី-កុមារីចំនួន១១១នាក់ ដែលត្រូវការការពិគ្រោះយោបល់ចិត្តសាស្ត្របានទទួលការតាមដានបន្តនៃការពិគ្រោះយោបល់ និងព្យាបាល |

| | | | |
|---|---|---|---|
| | យោបល់ និងព្យាបាលសុខភាពផ្លូវចិត្ត តាមករណីជាក់ស្តែងនីមួយ ៗ ។ | | សុខភាពផ្លូវចិត្តចំនួន២៦៣ដង(វគ្គ) តាមករណីជាក់ស្តែងនីមួយ ៗ ។ |
| 3.8.1.23 | យុវនារី-កុមារីចំនួន៨០នាក់ នឹងទទួលបានការព្យាបាលសុខភាពផ្លូវចិត្ត តាមបែបសកម្មភាពសីល្បះផ្សេង ៗ ចំនួន២៤វគ្គ ។ | 3.8.1.23 | យុវនារី-កុមារីចំនួន៧២នាក់ បានទទួលការព្យាបាលសុខភាពផ្លូវចិត្ត តាមបែបសកម្មភាពសីល្បះផ្សេង ៗ ចំនួន១៥វគ្គ ដូចជា ការគូររូបភាពជារង្វង់ចំនួន១វគ្គ ការគូររូបចំនួន៤វគ្គ ការគូរមុខចំនួន១វគ្គ ផាត់ពណ៌រូបភាពចំនួន៤វគ្គ ការបត់ក្រដាសធ្វើរូបផ្សេង ៗ ចំនួន៣វគ្គ និង ការផ្គុំរូប ចំនួន២វគ្គ ។ |
| 3.8.1.24 | យុវនារី-កុមារីចំនួន៨០នាក់ នឹងទទួលបានការបណ្តុះបណ្តាល ក្រុមជួយខ្លួនឯង ចំនួន៣៦វគ្គ លើប្រធានបទនៃការរំលោភបំពានការជួញដូរមនុស្ស អំពើហឹង្សាក្នុងគ្រួសារ គ្រួសារក្រីក្រ ខ្សោយសុខភាពផ្លូវចិត្ត/ការលូតលាស់របស់កុមារ ការផ្សារភ្ជាប់ជាមួយក្រុមគ្រួសារ និងការគាំទ្រអនាគត។ | 3.8.1.24 | យុវនារី-កុមារីចំនួន៥៥នាក់ បានទទួលវគ្គបណ្តុះបណ្តាលក្រុមជួយខ្លួនឯង បានចំនួន២២វគ្គ លើប្រធានបទការជឿជាក់លើខ្លួនឯង ការគ្រប់គ្រងកំហឹង ការកំណត់គោលដៅ ការយកចិត្តទុកដាក់លើខ្លួនឯង ការឆ្លុះបញ្ចាំងលើខ្លួនឯង ការយល់ដឹងពីខ្លួនឯង អារម្មណ៍ចង់វាយតប់ ជំហ៊ានទីមួយនៅតុលាការ ការបញ្ចេញអារម្មណ៍និងការគ្រប់គ្រងអារម្មណ៍ អារម្មណ៍អវិជ្ជមានលើអ្នកដទៃ និយាយវិជ្ជមានអំពីខ្លួនឯង និង នីតិវិធីនៅតុលាការ។ យើងអនុវត្តបានតិចជាងផែនការណ៍រំពឹងទុកដោយផលប៉ះពាល់បណ្តាលមកពីការរាតត្បាតមេរោគកូវី-១៩ដែលយើងត្រូវរក្សាគម្លាតសង្គម។ |
| 3.8.1.25 | យុវនារី-កុមារីចំនួន៨០នាក់ នឹងទទួលបានការបណ្តុះបណ្តាលអំពីការថែទាំសុខភាពផ្លូវចិត្តបឋមនិងការអប់រំបង្ការចំនួន២១វគ្គ អំពីប្រធានបទផ្សេងៗ។ | 3.8.1.25 | យុវនារី-កុមារីចំនួន៧១នាក់ បានទទួលវគ្គបណ្តុះបណ្តាលអំពីការថែទាំសុខភាពផ្លូវចិត្តបឋមនិងការអប់រំបង្ការចំនួន១២វគ្គ អំពីប្រធានបទការថែទាំខ្លួន សុជីវធម៌ បច្ចេកទេសក្នុងការសំរាក និងការគ្រប់គ្រងកំហឹង។ យើងអនុវត្តបានតិចជាងផែនការណ៍រំពឹងទុកដោយផលប៉ះពាល់បណ្តាលមកពីការរាតត្បាតមេរោគកូវី-១៩ដែលយើងត្រូវរក្សាគម្លាតសង្គម។ |
| 3.8.1.26 | យុវនារី-កុមារីចំនួន១៧៩នាក់ នឹងបានទទួលការតាមដានបន្ត ការពិគ្រោះយោបល់ចិត្ត | 3.8.1.26 | យុវនារី-កុមារីចំនួន៥៣នាក់បានទទួលការតាមដានបន្ត ការពិគ្រោះយោបល់ចិត្តសាស្ត្រ ដោ |

| | | | |
|---|---|---|---|
| | សាស្ត្រ ដោយផ្ទាល់ និង តាមទូរសព្ទ។ ក្នុងនោះចំនួន១០០នាក់ជាយុវនារី-កុមារីសមាហរណកម្ម ចំនួន៥០នាក់ជាអប់រំសហគមន៍ ចំនួន១៤នាក់ហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ និង ១២នាក់ទៀតជានិស្សិតអាហារូបករណ៍សកលវិទ្យាល័យ។ | | យផ្ទាល់ និង តាមទូរសព្ទចំនួន៨៧ដង។ ក្នុងនោះចំនួន២២នាក់ជាយុវនារី-កុមារីសមាហរណកម្ម ចំនួន១៨នាក់ជាអប់រំសហគមន៍ ចំនួន៦នាក់ហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ និង ៧នាក់ទៀតជានិស្សិតអាហារូបករណ៍សកលវិទ្យាល័យ។ យើងមិនអាចអនុវត្តបានតាមផែនការណ៍រំពឹងទុកដោយផលប៉ះពាល់បណ្តាលមកពីការរាតត្បាតមេរោគកូវី-១៩ ដែលយើងត្រូវរក្សាកម្លាតសង្គម និងការធ្វើដំណើរមានកំរិត។ |
| 3.8.1.27 | យុវនារី-កុមារីចំនួន៨០នាក់ស្នាក់នៅមណ្ឌលទុំឱ នឹងទទួលបានការហ្វឹកហ្វឺនយោគៈ (Yoga) ចំនួន១០៤វគ្គ ដោយហសការជាដៃគូរជាមួយអង្គការ Krama Yoga Cambodia ។ គំរោងនេះទទួលជំនួយឧបត្ថម្ភថវិកាពី Leslies Gutson ដោយផ្តល់ថវិកា ទៅអង្គការ Krama Yoga Cambodia ផ្ទាល់តែម្តង។ | 3.8.1.27 | យុវនារី-កុមារីចំនួន៨២នាក់បានទទួលការហ្វឹកហ្វឺនយោគៈចំនួន៥៥វគ្គ នៅក្នុងមណ្ឌលទុំឱ។ ដោយការរាតត្បាតនៃមេរោគកូវីដ១៩យើងមិនអនុញ្ញាតអោយលោកគ្រូអ្នកគ្រូ មកពីអង្គការ Krama Yoga ចូលមកបង្ហាត់យុវនារី-កុមារីនៅក្នុងមណ្ឌលទេ គឺយុវនារីធំៗ ជាពិសេសនិស្សិតអាហារូបករណ៍សកលវិទ្យាល័យបង្ហាត់យោគៈដល់យុវនារី-កុមារីនៅក្នុងមណ្ឌល។ យើងនឹងបន្តភាពជាដៃគូសហាការជាមួយអង្គការ Krama yoga សំរាប់ការហ្វឹកហ្វឺនយោគៈនៅពេលលណាការរាតត្បាតមេរោគគ្រប់គ្រងបាន។ យើងមិនអាចអនុវត្តបានតាមផែនការណ៍រំពឹងទុកដោយផលប៉ះពាល់បណ្តាលមកពីការរាតត្បាតមេរោគកូវី-១៩ ដែលយើងត្រូវរក្សាកម្លាតសង្គម។ |
| 3.8.1.28 | យុវនារី-កុមារីចំនួន៦១នាក់នឹងទទួលបានការពិគ្រោះយោបល់ចិត្តសាស្ត្រនៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេល ចូលឆ្លើយបំភ្លឺ និងចូលសវនាការនៅតុលាការ។ ក្នុងនោះ៣៦នាក់ ជាករណីសល់ពីចុងខែធ្នូឆ្នាំ២០២០ និង២៥នាក់ទៀតជាករណីពាក់ព័ន្ធផ្លូវច្បាប់ថ្មីក្នុងឆ្នាំ២០២១។ | 3.8.1.28 | យុវនារី-កុមារីចំនួន៧នាក់បានទទួលការពិគ្រោះយោបល់ចិត្តសាស្ត្រចំនួន៧ដងនៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេល ចូលឆ្លើយបំភ្លឺ និងចូលសវនាការនៅតុលាការ ។ យើងមិនអាចអនុវត្តបានតាមផែនការណ៍រំពឹងទុកដោយផលប៉ះពាល់បណ្តាលមកពីការរាតត្បាតមេរោគកូវី-១៩ ដែលយើងត្រូវរក្សាកម្លាតសង្គម ផ្អាកការធ្វើដំណើរចុះបេសកម្ម សុំតុលាការលើកពេលចូលបំភ្លឺនិងសវនាការ។ |

| | |
|---|---|
| 3.8.1.29 យុវនារី-កុមារីចូលថ្មីចំនួន២៥នាក់ នឹងទទួលបានការពិគ្រោះយោបល់ចិត្តសាស្ត្រ នៅអំឡុងពេល និងក្រោយពេលធ្វើនីតិវិធីប្រគល់-ទទួល។ | 3.8.1.29 យុវនារី-កុមារីចូលថ្មីចំនួន១៥នាក់ បានទទួលការពិគ្រោះយោបល់ចិត្តសាស្ត្រ នៅអំឡុងពេលនិងក្រោយពេលធ្វើនីតិវិធីប្រគល់-ទទួលចូលមណ្ឌលស្តារនីតិសម្បទាទុំឌី។ យើងមិនអាចអនុវត្តបានតាមផែនការណ៍រំពឹងទុកដោយផលប៉ះពាល់បណ្តាលមកពីការរាតត្បាតមេរោគកូវី-១៩ ដែលយើងត្រូវរក្សាគម្លាតសង្គម ផ្អាកការធ្វើដំណើរចុះបេសកម្មរបស់បុគ្គលិក។ |
| 3.8.1.30 គ្រួសាររបស់យុវនារី-កុមារីចំនួន៣០គ្រួសារ នឹងទទួលបានការពិគ្រោះយោបល់ចិត្តសាស្ត្រ ក្នុងអំឡុងពេលដំណើរការនីតិវិធីច្បាប់ នៅពេលចូលឆ្លើយបំភ្លឺ និងចូលសវនាការជំនុំជំរះនៅតុលាការ។ | 3.8.1.30 គ្រួសាររបស់យុវនារី-កុមារីចំនួន៨គ្រួសារបានទទួលការពិគ្រោះយោបល់ចិត្តសាស្ត្រក្នុងអំឡុងពេលដំណើរការនីតិវិធីច្បាប់ នៅពេលចូលឆ្លើយបំភ្លឺចំនួន៦ដង និងចូលសវនការជំនុំជំរះចំនួន២ដងនៅតុលាការ។ ដោយការរាតត្បាតមេរោគកូវី-១៩ យើងត្រូវរក្សាគម្លាតសង្គម ផ្អាកការធ្វើដំណើរចុះបេសកម្ម សុំតុលាការលើកពេលចូលបំភ្លឺនិងសវនាការ ទើបយើងមិនអាចសំរេចបានតាមផែនការណ៍កំណត់។ |
| 3.8.1.31 គ្រួសាររបស់យុវនារី-កុមារីចំនួន២០គ្រួសារ នឹងទទួលបានការពិគ្រោះយោបល់ចិត្តសាស្ត្រ ពីបុគ្គលិកចិត្តសាស្ត្ររបស់យើង តាមតម្រូវការជាក់ស្តែង នៅពេលដំណើរការនីតិវិធីប្រគល់-ទទួលជនរងគ្រោះចូលថ្មី។ | 3.8.1.31 គ្រួសាររបស់យុវនារី-កុមារីចំនួន៨គ្រួសារបានទទួលការពិគ្រោះយោបល់ចិត្តសាស្ត្រ ពីបុគ្គលិកចិត្តសាស្ត្ររបស់យើង ក្នុងអំឡុងពេលដំណើរការនីតិវិធីប្រគល់-ទទួលជនរងគ្រោះចូលថ្មីមកកាន់មណ្ឌលស្តារនីតិសម្បទាទុំឌី។ ដោយការរាតត្បាតមេរោគកូវី-១៩ យើងត្រូវរក្សាគម្លាតសង្គម និងផ្អាកការធ្វើដំណើរចុះបេសកម្ម ទើបយើងមិនអាចសំរេចបានតាមផែនការណ៍។ |
| 3.8.1.32 វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពបុគ្គលិក សំរាប់បុគ្គលិកចិត្តសាស្ត្រ ចំនួន២នាក់ តាមប្រព័ន្ធអនឡាញ អំពីEMDR និងមិត្តជួយមិត្តចំនួន១១ដង ។ | 3.8.1.32 យើងមិនបានអនុវត្តសកម្មភាពវគ្គបណ្តុះបណ្តាលមិត្តជួយមិត្ត និងEMDR តាមប្រព័ន្ធអនឡាញសំរាប់បុគ្គលិកចិត្តសាស្ត្រ២នាក់ទេ ដោយបញ្ហាសុខភាពគ្រូបង្វឹកនិងការរាតត្បាតមេរោគកូវីដ១៩ ។ |
| **គាំពារនីតិកម្ម ( ជំនួយផ្នែកច្បាប់ )** | |

| | | | |
|---|---|---|---|
| 3.8.1.33 | យុវនារី-កុមារីចូលថ្មីចំនួនចំនួន២៥នាក់ មកកាន់មណ្ឌលស្តារនីតិសម្បទាទុំឌី ដែលពាក់ព័ន្ធនីតិវិធីច្បាប់ នឹងទទួលបានជំនួយផ្នែកច្បាប់តាមនីតិវិធីនៅតុលាការ។ | 3.8.1.33 | យុវនារី-កុមារីចូលថ្មីចំនួន៣៨នាក់ បានទទួលជំនួយផ្នែកច្បាប់តាមនីតិវិធីច្បាប់នៅតុលាការ។ ក្នុងនោះ១៧នាក់ជាករណីសល់ពីចុងខែធ្នូឆ្នាំ២០២០និង២១នាក់ទៀតជាករណីពាក់ព័ន្ធផ្លូវច្បាប់ថ្មីក្នុងឆ្នាំ២០២១។<br><br>ជនសង្ស័យចំនួន៣២នាក់ត្រូវបានចាប់ឃុំខ្លួនរងចាំសវនាការ។ ក្នុងនោះ១៦នាក់ជាករណីចាប់ឃុំខ្លួនក្នុងឆ្នាំ២០២០ និង១៦នាក់ទៀតជាករណីចាប់ឃុំខ្លួនក្នុងឆ្នាំ២០២១។ |
| 3.8.1.34 | យើងនឹងស្នើសុំមេធាវីចំនួន២៥ (២នាក់នឹងជួលពីក្រុមហ៊ុនមេធាវីឯកជន) ពីបណ្តាអង្គការ ស្ថាប័នដៃគូបំរើសេវាកម្មច្បាប់ ដើម្បីជាតំណាង ការពារក្តីអោយជនរងគ្រោះ នៅតុលាការតាមនីតិវិធីច្បាប់។ | 3.8.1.34 | យើងបានស្នើសុំមេធាវីចំនួន២២នាក់ ពីបណ្តាអង្គការ ស្ថាប័នដៃគូដែលបំរើសេវាកម្មច្បាប់ដើម្បីជាតំណាង ការពារក្តីអោយជនរងគ្រោះនៅតុលាការតាមនីតិវិធីច្បាប់ ។ ក្នុងនោះយើងបានស្នើសុំមេធាវីពីអង្គការ CPU AIM Chab Dai និងក្រុមមេធាវីស្ម័គ្ររបស់**សម្តេចតេជោ ហ៊ុន សែន**។ ថ្វីបើចំនួនមេធាវីការពារក្តីជនរងគ្រោះមានចំនួនតិចជាងផែនការណ៍រំពឹងរបស់យើងមែន តែយុវនារី-កុមារីរងគ្រោះទាំងអស់សុទ្ធតែមានមេធាវីការពារក្តីតាមនីតិវិធីច្បាប់។ |
| 3.8.1.35 | យុវនារី-កុមារីរងគ្រោះដោយការរំលោភសេពសន្ថវៈនឹងបានទទួលការធ្វើកោសល្យវិច្ច័យ ដើម្បីជាភស្តុតាង ដាក់បន្ទុកប្រឆាំង (លើ) ជនជាប់ចោទ។ | 3.8.1.35 | យុវនារី-កុមារីរងគ្រោះដោយការរំលោភសេពសន្ថវៈចំនួន២០នាក់ បានទទួលការធ្វើកោសល្យវិច្ច័យ ដើម្បីបញ្ជាក់ជាភស្តុតាងដាក់បន្ទុកប្រឆាំងជនជាប់ចោទនៅតុលាការ។ |
| 3.8.1.36 | យុវនារី-កុមារីរងគ្រោះចំនួន៦០នាក់នឹងទៅចូលឆ្លើយបំភ្លឺ និងចូលសវនាការចំនួន៦០ដងនៅតុលាការតាមការដីការកោះបង្គាប់របស់តុលាការ (ជាទូទៅកុមាររងគ្រោះ១នាក់ត្រូវចូលឆ្លើយបំភ្លឺ១ដងនិងចូលសវនាការ១ដងប៉ុន្តែមានករណីខ្លះអាចលើសពី២ដង)។ | 3.8.1.36 | យុវនារី-កុមារីរងគ្រោះចំនួន១៨នាក់បានចូលឆ្លើយបំភ្លឺចំនួន១០ដងនិងចូលសវនាការចំនួន៩ដង។ ក្នុងនោះយុវនារី-កុមារីរងគ្រោះចំនួន៨នាក់ បានចូលឆ្លើយបំភ្លឺចំនួន១០ដង និងយុវនារី-កុមារីចំនួន១០នាក់បានចូលសវនាការចំនួន៩ដង ។ ជនជាប់ចោទចំនួន៨នាក់ ត្រូវបានតុលាការកាត់ទោសអោយជាប់ព័ន្ធនាគារកំរិតទោសខ្ពស់បំផុត១៣ឆ្នាំ និងទាបបំផុត ៥ឆ្នាំ។ សំណងរដ្ឋប្បវេណីច្រើនបំផុត២០លានរៀល |

| | |
|---|---|
| | និងតិចបំផុត៨លានរៀល ។ ប៉ុន្តែជនរងគ្រោះមិនដែលទទួលបានសំណងរដ្ឋប្បវេណីទេ។ យើងមិនអាចអនុវត្តបានតាមផែនការណ៍រំពឹងទុក ដោយផលប៉ះពាល់បណ្តាលមកពីការរាតត្បាតមេរោគកូវី-១៩ ដែលយើងត្រូវរក្សាគម្លាតសង្គម ផ្អាកការធ្វើដំណើរចុះបេសកម្ម សុំតុលាការលើកពេលចូលបំភ្លឺនិងសវនាការ។ល។ |
| 3.8.1.37 យើងនឹងធ្វើការតាមដានករណីពាក់ព័ន្ធ និងនីតិវិធីច្បាប់ ចំនួន៣០០ដងជាមួយមេធាវី ។ ការតាមដានបន្តភាគច្រើននឹងធ្វើតាមទូរស័ព្ទ។ | 3.8.1.37 យើងបានធ្វើការតាមដានករណី យុវនារី-កុមារីរងគ្រោះដែលពាក់ព័ន្ធនីតិវិធីច្បាប់បានចំនួន ១៩០ដង ជាមួយមេធាវីភាគច្រើនយើងធ្វើតាមរយៈទូរស័ព្ទ។ |
| 3.8.1.38 យើងនឹងមានការប្រជុំចំនួន២៥ដងជាមួយមន្ត្រីមន្ទីរសង្គមកិច្ចខេត្ត-ក្រុង និងអាជ្ញាធរមូលដ្ឋាន អំពីការប្រគល់-ទទួលករណីយុវនារី-កុមារីរងគ្រោះក្នុងឆ្នាំ២០២១។ | 3.8.1.38 យើងបានប្រជុំជាមួយមន្ត្រីមន្ទីរសង្គមកិច្ចខេត្ត-ក្រុង និងអាជ្ញាធរមូលដ្ឋានបានចំនួន២៣ដង អំពីការប្រគល់-ទទួលករណីយុវនារី-កុមារីរងគ្រោះមកអង្គការអាហ្វេស៊ីប-កម្ពុជាក្នុងឆ្នាំ ២០២១។ |
| **៣.៨.២ កម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញខាងក្រៅ**<br><br>**អប់រំក្នុងប្រព័ន្ធខណៈកុមារីស្នាក់នៅមណ្ឌល**<br><br>3.8.2.1 យុវនារី-កុមារីចំនួន៧៥នាក់ នឹងទទួលបានការសិក្សាអប់រំក្នុងប្រព័ន្ធនៅសាលារដ្ឋ ។ | 3.8.2.1 យុវនារី-កុមារីចំនួន៦២នាក់ បានទទួលការសិក្សាអប់រំក្នុងប្រព័ន្ធនៅសាលារដ្ឋ ។ ក្នុងនោះកុមារីចំនួន៥៦នាក់សល់ពីចុងឆ្នាំ២០២០ និង ៦នាក់ទៀត ជាករណីកុមារីចូលរៀនថ្មីក្នុងឆ្នាំ ២០២១។ យើងអនុវត្តសកម្មភាពនេះមិនបានគ្រប់តាមផែនការណ៍រំពឹងទុក គឺដោយសារផលប៉ះពាល់នៃការរាតត្បាតមេរោគកូវីដ១៩៖<br>- ៤៣នាក់ សិក្សានៅបឋមសិក្សា<br>- ១៣នាក់ សិក្សានៅមធ្យមសិក្សា<br>- ៦នាក់ សិក្សានៅវិទ្យាល័យ |

| | |
|---|---|
| 3.8.2.2 យុវនារី-កុមារីចំនួន៧០នាក់នឹងទទួលបានការសិក្សាភាសាអង់គ្លេស នៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី ។ ក្នុងនោះចំនួន៦០នាក់ជាយុវនារី-កុមារីស្នាក់នៅក្នុងមណ្ឌល និង១០នាក់ទៀតជាកុមារីសហគមន៍។<br><br>3.8.2.3 យុវនារី-កុមារីចំនួន៨០នាក់នឹងទទួលបានការសិក្សាថ្នាក់មូលដ្ឋានកំព្យូទ័រ នៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី។ ក្នុងនោះ១០នាក់ជាកុមារីមកពីសហគមន៍ ។<br><br>3.8.2.4 យុវនារី-កុមារីចំនួន៩០នាក់នឹងចូលអានសៀវភៅ និង ធនធានអប់រំផ្សេង ៗ នៅក្នុងបណ្ណាល័យ។ | 3.8.2.2 យុវនារី-កុមារីចំនួន៧៩នាក់បានទទួលការសិក្សាភាសាអង់គ្លេស នៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី ។ ក្នុងនោះចំនួន៦នាក់ជានិស្សិតអាហារូបករណ៍សកលវិទ្យា ។ ដោយសារការរាតត្បាតមេរោគកូវីដ-១៩ យើងមិនបានអនុញ្ញាតអោយកុមារីសហគមន៍ចូលរៀនភាសាអង់គ្លេសនៅក្នុងមណ្ឌលទេ។<br><br>3.8.2.3 យុវនារី-កុមារីចំនួន៨៣នាក់បានទទួលការសិក្សាថ្នាក់មូលដ្ឋានកំព្យូទ័រ នៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី។ ក្នុងនោះ៦នាក់ជានិស្សិតអាហារូបករណ៍សកលវិទ្យាល័យ ។ ដោយសារការរាតត្បាតមេរោគកូវីដ-១៩ យើងមិនបានអនុញ្ញាតអោយកុមារីសហគមន៍ចូលរៀនកុំព្យូទ័រនៅក្នុងមណ្ឌលទេ។<br><br>3.8.2.4 យុវនារី-កុមារីចំនួន៦២នាក់បានចូលអានសៀវភៅ និងធនធានអប់រំផ្សេង ៗ នៅក្នុងបណ្ណាល័យនៅមណ្ឌលស្តារនីតិសម្បទាទុំឌី។ |
| **កម្មវិធីអប់រំនៅសហគមន៍**<br><br>3.8.2.5 យុវនារី-កុមារីចំនួន៧០នាក់នឹងទទួលបានការឧបត្ថម្ភឯកសណ្ឋានសិស្ស និង សម្ភារៈសិក្សា ។ ក្នុងនោះ៥០នាក់ជាយុវនារី-កុមារីសល់ពីចុងឆ្នាំ២០២០ និង២០នាក់ទៀតជាយុវនារី-កុមារីសិក្សាអប់រំសហគមន៍ថ្មីក្នុងឆ្នាំ២០២១ ។ | 3.8.2.5 យុវនារី-កុមារីចំនួន៥៨នាក់បានទទួលការឧបត្ថម្ភអប់រំសហគមន៍ពីអង្គការអាហ្វេស៊ីប-កម្ពុជា ។ ក្នុងនោះយុវនារី-កុមារីចំនួន៥០នាក់សល់ពីចុងខែធ្នូ ឆ្នាំ២០២០ និង៨នាក់ទៀតជាយុវនារី-កុមារីអប់រំសហគមន៍ថ្មីក្នុងឆ្នាំ២០២១ ។ ៣នាក់បានចូលហ្វឹកហ្វឺនជំនាញខាងក្រៅ ១នាក់បានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ បន្តឧត្តម្ភសិក្សានៅសកលវិទ្យាល័យ និង៥នាក់ទៀតបានបោះបង់ការសិក្សា ដោយមូលហេតុផ្សេងៗ ។ យុវនារី-កុមារីអប់រំសហគមន៍ចំនួន៤៩នាក់កំពុងបន្តការសិក្សានៅឆ្នាំ២០២២។<br>- ៣១នាក់ បានសិក្សានៅបឋមសិក្សា<br>- ១៥នាក់ បានសិក្សានៅមធ្យមសិក្សា<br>- ១២នាក់ បានសិក្សានៅវិទ្យាល័យ |

| | |
|---|---|
| 3.8.2.6 យុវនារី-កុមារីរៀនថ្នាក់ទី១២ ចំនួន១នាក់ និងថ្នាក់ទី៩ ចំនួន៦នាក់។ សរុបទាំងអស់ចំនួន៧នាក់នឹងរៀនបន្ថែមលើមុខវិជ្ជាផ្សេងៗ ប៉ុន្តែដោយបញ្ហាកង្វះខាតថវិកាយើងមិនអាចបង់ថ្លៃសិក្សាជូនពួកគាត់បានទេ ដូច្នេះពួកគាត់ត្រូវយកប្រាក់ឧបត្ថម្ភប្រចាំខែពីសម្តេចនៅបង់ថ្លៃសិក្សាបន្ថែមនេះ។ | 3.8.2.6 យុវនារី-កុមារីសិក្សាថ្នាក់ទី៩ ចំនួន១នាក់បានរៀនបន្ថែមលើមុខវិជ្ជាមួយចំនួនដោយប្រើប្រាស់ថវិកាសម្តេចឧបត្ថម្ភប្រចាំខែ ។ |
| 3.8.2.7 យុវនារី-កុមារីអប់រំសហគមន៍ចំនួន២០នាក់នឹងទទួលបានការឧបត្ថម្ភកង់ ទាំងយុវនារី-កុមារីអប់រំសហគមន៍ថ្មី និងអ្នកមានកងខូចសំរាប់ជាមធ្យោបាយធ្វើដំណើរ ទៅសាលារៀនប្រចាំថ្ងៃរបស់ពួកគាត់។ | 3.8.2.7 យុវនារី-កុមារីអប់រំសហគមន៍ចំនួន៩នាក់បានទទួលការឧបត្ថម្ភកង់ សំរាប់ជាមធ្យោបាយធ្វើដំណើរ ទៅសាលារៀនប្រចាំថ្ងៃរបស់ពួកគាត់។ ក្នុងនោះ៧នាក់ជាករណីថ្មី និង២នាក់ទៀតប្តូរកង់ចាស់ខូចមិនអាចជួសជុលបាន។ |
| 3.8.2.8 យុវនារី-កុមារីអប់រំសហគមន៍ចំនួន៧០នាក់នឹងទទួលបានការពិនិត្យតាមដានបន្តដោយការចុះជួបផ្ទាល់ និងតាមរយៈទូរស័ព្ទចំនួន២៦៤ដង។ | 3.8.2.8 យុវនារី-កុមារីអប់រំសហគមន៍ចំនួន៥៥នាក់បានទទួលការពិនិត្យតាមដានបន្តដោយការចុះជួបផ្ទាល់ និងតាមរយៈទូរស័ព្ទ ចំនួន១៨៨ដង។ |
| 3.8.2.9 គ្រួសាររបស់យុវនារី-កុមារីអប់រំសហគមន៍ចំនួន៣គ្រួសារនឹងទទួលបានការឧបត្ថម្ភគ្រួសារពីអង្គការអាហ្វេស៊ីប-កម្ពុជា តាមតម្រូវការជាក់ស្តែងរបស់ករណីនីមួយ ៗ ។ | 3.8.2.9 គ្រួសាររបស់យុវនារី-កុមារីអប់រំសហគមន៍ចំនួន១គ្រួសារ( PP-៣៤៥៦ )បានទទួលបានការឧបត្ថម្ភគ្រួសារពីអង្គការអាហ្វេស៊ីប-កម្ពុជា ដើម្បីពង្រឹងមុខរបរបច្ចុប្បន្នរបស់ពួកគាត់ អោយមានលំក្នុងការរកចំណូលផ្គត់ផ្គង់ដល់កុមារីអប់រំសហគមន៍ ។ |
| 3.8.2.10 យុវនារី-កុមារីអប់រំសហគមន៍ចំនួន២៥នាក់នឹងទទួលបានការឧបត្ថម្ភប្រាក់ហោប៉ៅប្រចាំខែពីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ | 3.8.2.10 យុវនារី-កុមារីអប់រំសហគមន៍ចំនួន២៥នាក់បានទទួលការឧបត្ថម្ភប្រាក់ហោប៉ៅប្រចាំខែពីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ |
| **និស្សិតអាហារូបករណ៍សកលវិទ្យាល័យ**<br>3.8.2.11 និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន១២នាក់ រាប់បញ្ចូលទាំងនិស្សិត១ | 3.8.2.11 និស្សិតអាហារូបករណ៍ចំនួន១២នាក់បានទទួលការឧបត្ថម្ភពីអង្គការអាហ្វេស៊ីប-កម្ពុជា។ |

| | | | |
|---|---|---|---|
| | នាក់កំពង់សិក្សានាយទាហានសកម្មនៅសកលវិទ្យាល័យក្រសួងការពារជាតិ នឹងទទួលបានការឧបត្ថម្ភ។ ១១នាក់នឹងទទួលបានការឧបត្ថម្ភថ្លៃសិក្សា។ ក្នុងនោះ៣នាក់ជានិស្សិតអាហារូបករណ៍ថ្មីក្នុងឆ្នាំ២០២១ និង៩នាក់ទៀតជានិស្សិតពីឆ្នាំ២០២០។ | | និស្សិត៩នាក់សល់ពីចុងខែធ្នូ ឆ្នាំ២០២០ និង៣នាក់ទៀតជានិស្សិតថ្មីក្នុងឆ្នាំ២០២១។ និស្សិត១១នាក់បានទទួលការឧបត្ថម្ភថ្លៃសិក្សា ការរស់នៅប្រចាំខែ និងការថែទាំសុខភាព។<br><br>និស្សិតទាំងនេះកំពុងសិក្សាលើមុខវិជ្ជាច្បាប់ និងសេដ្ឋកិច្ច អក្សរសាស្ត្រអង់គ្លេស ព័ត៌មានវិជ្ជា រដ្ឋបាលពាណិជ្ជកម្ម ទីផ្សារនិងទំនាក់ទំនង អក្សរសាស្ត្រខ្មែរ គ្រប់គ្រង រដ្ឋបាលសាធារណៈ ការគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច នាយទាហានសកម្មនៅសកលវិទ្យាល័យក្រសួងការពារជាតិ។<br><br>ក្នុងនោះ៣នាក់កំពុងសិក្សាឆ្នាំទី១ ២នាក់កំពុងសិក្សាឆ្នាំទី២ ៤នាក់កំពុងសិក្សាឆ្នាំទី៣ និង៣នាក់ទៀតកំពុងសិក្សាឆ្នាំទី៤។<br><br>៥នាក់ក្នុងចំណោម១២នាក់មានការងារធ្វើដោយសិក្សាផង ធ្វើការផង គឺដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់តម្រូវការផ្ទាល់ខ្លួនក៏ដូចជាជួយដល់ក្រុមគ្រួសារផងដែរ៖<br>- KC-00៦២ មានការងារពេញម៉ោងជាគ្រូបង្រៀនភាសាអង់គ្លេសនៅសាលាឯកជនមីគីវ៉េ។<br>- SR-0៥៣៧ មានការងារពេញម៉ោងជាបុគ្គលិកផ្នែកទទួលភ្ញៀវនៅអាគារប៊ិស្ស។<br>- KC-00៧៩ KC-00៤0 និងPP-៣២១៨ ជាបុគ្គលិកផ្នែកលក់អាហារបំប៉ន (យូស៊ី) របស់ក្រុមហ៊ុនសម្រស់ធម្មជាតិតាមអនឡាញ។ |
| 3.8.2.12 | និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន៨នាក់នឹងទទួលបានការឧបត្ថម្ភកំព្យូទ័រយួរដៃ ១នាក់ ១គ្រឿង សំរាប់ជាជំនួយដល់ការសិក្សារបស់ពួកគាត់។ | 3.8.2.12 | និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន៦នាក់បានទទួលការឧបត្ថម្ភកំព្យូទ័រយួរដៃ ១នាក់ ១គ្រឿង សំរាប់ជាជំនួយដល់ការសិក្សារបពួកគាត់។ ក្នុងនោះ២គ្រឿងជាកុំព្យូទ័រយួរដៃថ្មី និង៤គ្រឿងទៀតជាកុំព្យូទ័រយួរដៃមួយទឹក។ |

| | |
|---|---|
| 3.8.2.13 និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន១១នាក់ នឹងទទួលបានការឧបត្ថម្ភការសិក្សាភាសាអង់គ្លេសនៅសាលាឯកជន ។ | 3.8.2.13 និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន៦នាក់ បានទទួលការឧបត្ថម្ភការសិក្សាភាសាអង់គ្លេស នៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី ព្រោះដោយបញ្ហារាតត្បាតមេរោគកូវីដ-១៩ ពួកគាត់មិនអាចចេញទៅសិក្សានៅខាងក្រៅបានទេ។ |
| 3.8.2.14 និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន១១នាក់ នឹងទទួលបានការឧបត្ថម្ភការសិក្សាកុំព្យូទ័រ ។ | 3.8.2.14 និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន៦នាក់ បានទទួលការឧបត្ថម្ភការសិក្សាកុំព្យូទ័រ នៅក្នុងមណ្ឌលស្តារនីតិសម្បទាទុំឌី ព្រោះដោយបញ្ហារាតត្បាតមេរោគកូវីដ-១៩ ពួកគាត់មិនអាចចេញទៅសិក្សានៅខាងក្រៅបានទេ។ |
| 3.8.2.15 ស្សិតអាហារូបករណ៍សកលវិទ្យាល័យថ្មីចំនួន៣នាក់នឹងទទួលបានឧបត្ថម្ភកញ្ចប់សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ។ | 3.8.2.15 ស្សិតអាហារូបករណ៍សកលវិទ្យាល័យថ្មីចំនួន៣នាក់បានទទួលការឧបត្ថម្ភកញ្ចប់សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនប្រចាំថ្ងៃ។ |
| 3.8.2.16 និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន១២ នឹងទទួលបានការពិនិត្យតាមដានជាទៀងទាត់ចំនួន១២០ដង ។ | 3.8.2.16 និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន១២នាក់ បានទទួលការពិនិត្យតាមដានជាទៀងទាត់ចំនួន១៨៤ដង។ ការត្រួតពិនិត្យតាមដានផ្តោតលើវឌ្ឍនភាពនៃការសិក្សា បញ្ហាប្រឈមរបស់និស្សិតម្នាក់ ៗ បញ្ហាសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត។ |
| **ហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈនៅខាងក្រៅ** | |
| 3.8.2.17 យុវនារីហ្វឹកហ្វឺនខាងក្រៅចំនួន១៤នាក់នឹងទទួលបានការឧបត្ថម្ភថ្លៃហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ ។ ក្នុងនោះ៤នាក់សល់ពីឆ្នាំ២០២០ និង១០នាក់ទៀតជាករណីយុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅថ្មីក្នុងឆ្នាំ២០២១។ | 3.8.2.17 យុវនារីហ្វឹកហ្វឺនខាងក្រៅចំនួន១៥នាក់បានទទួលការឧបត្ថម្ភថ្លៃហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ និងថ្លៃការរស់នៅប្រចាំខែ។ ក្នុងនោះ៤នាក់សល់ពីចុងខែធ្នូ ឆ្នាំ២០២០ និង១១នាក់ទៀតជាករណីយុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅថ្មីក្នុងឆ្នាំ២០២១។ ២នាក់បានបោះបង់ការសិក្សា ៣នាក់បានបញ្ចប់ការហ្វឹកហ្វឺនដោយជោគជ័យ និង១០នាក់ទៀតកំពុងហ្វឹកហ្វឺនបន្តទៅឆ្នាំ២០២២។ |

| | |
|---|---|
| | ពួកគាត់ហ្វឹកហ្វឺនជំនាញទេសចរណ៍និងបដិសណ្ឋារកិច្ចនៅអង្គការក្ដីសង្ឃឹមខ្មែរស្ថិតនៅក្នុងស្រុកឪរ៉ាល់ខេត្តកំពង់ស្ពឺ ជំនាញកាត់ដេរនៅហាងកាត់សំលៀកបំពាក់ម៉េងហ័រនៅរាជធានីភ្នំពេញ ជំនាញអ៊ុតសក់នៅហាងចាស្មីន ហាងអ៊ុតសក់វ៉ាន់ណារីនៅខេត្តសៀមរាប ហាងដាឡែននៅរាជធានីភ្នំពេញ និងជំនាញចុងភៅនៅសាលាចុងភៅខេអេសខេនៅរាជធានីភ្នំពេញ។ |
| 3.8.2.18 យុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅចំនួន១៤នាក់នឹងទទួលបានការតាមដានបន្តចំនួន ១០០ដង ។ យុវនារី១នាក់នឹងទទួលបានការតាមដាន១ដងក្នុង១ខែ ។ សកម្មភាពនៃការតាមដាននឹងធ្វើតាមរយៈការចុះជួបផ្ទាល់និងតាមទូរស័ព្ទ ដោយផ្ដោតលើវឌ្ឍនភាពនៃការហ្វឹកហ្វឺនជំនាញ បញ្ហាប្រឈម និងស្ថានភាពនៃការរស់នៅ។ | 3.8.2.18 យុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅចំនួន១៥នាក់បានទទួលការតាមដានបន្តចំនួន៨១ដង ។ សកម្មភាពនៃការតាមដានបន្តតាមរយៈការចុះជួបផ្ទាល់ និងតាមទូរស័ព្ទ ដោយផ្ដោតលើវឌ្ឍនភាពនៃការហ្វឹកហ្វឺនជំនាញ បញ្ហាប្រឈម សុខភាពនិងស្ថានភាពនៃការរស់នៅ។ ការតាមដានបន្តបានតិចជាងផែនការណ៍រំពឹងទុកបណ្ដាលមកពីការរាតត្បាតមេរោគកូវីដ-១៩។ |
| 3.8.2.19 បទបង្ហាញតម្រង់ទិស ចំនួន១០ដងនឹងធ្វើបទបង្ហាញដល់យុវនារី ដែលមានបំណងចង់ហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ ដើម្បីជួយជាជំនួយដល់ការសំរេចចិត្ត តាមឆន្ទៈរបស់ពួកគាត់ ក្នុងការជ្រើសរើសជំនាញអោយបានត្រឹមត្រូវសំរាប់អនាគត។ | 3.8.2.19 បទបង្ហាញតម្រង់ទិសចំនួន១១ដង បានធ្វើឡើងដល់យុវនារីចំនួន១១នាក់ ដែលមានបំណងចង់ហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ ដើម្បីជួយជាជំនួយដល់ការសំរេចចិត្ត តាមឆន្ទៈរបស់ពួកគាត់ ក្នុងការជ្រើសរើសជំនាញអោយបានត្រឹមត្រូវសំរាប់អនាគត។ |
| 3.8.2.20 យុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅនឹងទទួលបានការឧបត្ថម្ភការរស់នៅប្រចាំខែ។ | 3.8.2.20 យុវនារីហ្វឹកហ្វឺនជំនាញខាងក្រៅចំនួន១៤នាក់បានទទួលការឧបត្ថម្ភប្រចាំខែ សំរាប់ទ្រទ្រង់ការរស់នៅប្រចាំថ្ងៃរបស់ពួកគេ រីឯយុវនារី១នាក់ទៀតបានទទួលការឧបត្ថម្ភពីអង្គការមួយនៅក្នុងសហគមន៍របស់នាង។ |
| 3.8.2.21 នឹងធ្វើបច្ចុប្បន្នភាពបញ្ជីរាយឈ្មោះហាងផ្តល់សេវាកម្មវិជ្ជាជីវៈហ្វឹកហ្វឺនជំនាញខាងក្រៅ។ | 3.8.2.21 យើងបានកត់ត្រាហាងថ្មីផ្តល់សេវាកម្មវិជ្ជាជីវៈហ្វឹកហ្វឺនជំនាញចំនួន៧ហាងចូលក្នុងបញ្ជីរាយឈ្មោះហាងហ្វឹកហ្វឺនជំនាញខាងក្រៅក្នុងឆ្នាំ ២០២១។ |
| | 3.8.2.22 យើងមិនបានអនុវត្តសកម្មភាពនេះទេដោយបញ្ហារាតត្បាតមេរោគកូវីដ-១៩។ |

| | |
|---|---|
| 3.8.2.22 នឹងផ្តល់ការបណ្តុះបណ្តាលការថែទាំសុខភាពបឋមវគ្គខ្លី១វគ្គស្តីអំពីសុខភាពបន្តពូជដោយសហការជាមួយកម្មវិធីសុខភាព។<br><br>3.8.2.23 នឹងផ្តល់ការបណ្តុះបណ្តាលវគ្គខ្លី១វគ្គស្តីអំពីសុខភាពផ្លូវចិត្តដោយសហការជាមួយកម្មវិធីចិត្តសាស្រ្ត។ | 3.8.2.23 យើងមិនបានអនុវត្តសកម្មភាពនេះទេដោយបញ្ហារាតត្បាតមេរោគកូវីដ-១៩។ |
| **៣.៨.៣ កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច**<br><br>3.8.3.1 យុវនារី-កុមារីចំនួន៨០នាក់ នឹងទៅលេងគ្រួសារចំនួន១២០ដង ។ ការទៅលេងគ្រួសាររបស់យុវនារី-កុមារីតែងតែធ្វើឡើងនៅពេលចូលឆ្នាំប្រពៃណីជាតិខ្មែរនិងបុណ្យភ្ជុំបិណ្ឌ។<br><br>3.8.3.2 យុវនារីចំនួន១៤នាក់ដែលបានបញ្ចប់ការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅដែលពួកគាត់បានជ្រើសរើសចប់ដោយជោគជ័យនឹងសមាហរណកម្មដោយឧបត្ថម្ភការបង្កើតមុខរបរខ្នាតតូចចំនួន(៤)នាក់ ឬ ការងារចំនួន(១០)នាក់។<br><br>3.8.3.3 យុវនារី-កុមារីសមាហរណកម្មចំនួន១៣៩នាក់ នឹងទទួលបានការតាមដានបន្តចំនួន៣០០ដង ដោយការចុះផ្ទាល់(៦០នាក់) និងតាមរយៈទូរស័ព្ទ។<br><br>3.8.3.4 គ្រួសារយុវនារី-កុមារីចំនួន៦គ្រួសារ (អប់រំសហគមន៍៣គ្រួសារ និងស្នាក់នៅមណ្ឌល៣គ្រួសារ) នឹងទទួលបានការឧបត្ថម្ភគ្រួសារតាមតម្រូវការជាក់ស្តែង។ | 3.8.3.1 យុវនារី-កុមារីចំនួន២២នាក់ បានទៅលេងគ្រួសារចំនួន២៧ដង នៅក្នុងឆ្នាំ២០២១។ ការទៅលេងគ្រួសារមានចំនួនតិចជាងការរំពឹងទុកបណ្តាលមកពីការរាតត្បាតមេរោគកូវីដ-១៩ ប៉ុន្តែយើងបានបង្កលក្ខណៈជួបគ្រួសារតាមទូរស័ព្ទបានច្រើន។<br><br>3.8.3.2 យុវនារីចំនួន៦នាក់ដែលបានបញ្ចប់ការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅដែលពួកគាត់បានជ្រើសរើសបានធ្វើសមាហរណកម្ម។ ៤នាក់បានសមាហរណកម្មដោយឧបត្ថម្ភការងារ និង២នាក់ទៀតបានសមាហរណកម្មទៅគ្រួសារវិញដោយមិនទាន់បានឧបត្ថម្ភនៅឡើយក្នុងឆ្នាំ២០២១។<br><br>3.8.3.3 យុវនារី-កុមារីសមាហរណកម្មចំនួន៥០នាក់បានទទួលការតាមដានបន្តចំនួន១៦៥ដងទាំងការចុះជួបផ្ទាល់និងតាមរយៈទូរស័ព្ទ។ យើងមិនអាចអនុវត្តបានតាមសុច្ចនៈកររំពឹងទុកបណ្តាលមកពីផលប៉ះពាល់នៃមេរោគកូវីដ-១៩។<br><br>3.8.3.4 គ្រួសារយុវនារី-កុមារីចំនួន២គ្រួសារ បានទទួលការឧបត្ថម្ភគ្រួសារ។ គ្រួសារករណីPP-៣៤៤៦ (អប់រំសហគមន៍)បានទទួលការឧបត្ថម្ភគ្រួសារចំនួន២០០ដុល្លារអាមេរិកសំរាប់ការពង្រីកមុខរបរ និងគ្រួសារករណីPP-៣៣៩៩ |

| | |
|---|---|
| | បានទទួលការឧបត្ថម្ភគ្រួសារចំនួន៣៥៩១ដុល្លារអាមេរិកសំរាប់សាងសង់ផ្ទះលើដីដែលអាជ្ញាធរមូលដ្ឋានបានទិញអោយ(ថវិកាសប្បុរសជន)។ |
| 3.8.3.5 យុវនារី-កុមារីសេមាហរណកម្មចំនួន១៥នាក់នឹងទទួលបានការឧបត្ថម្ភជំនួយបន្ថែមតាមតម្រូវការជាក់ស្តែង។ | 3.8.3.5 យុវនារី-កុមារីសមាហរណកម្មចំនួន៥នាក់បានទទួលការឧបត្ថម្ភជំនួយបន្ថែម ក្រោយពេលសមាហរណកម្ម។ ករណីSR-០៣០៤ទទួលបានការឧបត្ថម្ភចំនួន៣០.៧៥ដុល្លារអាមេរិកសំរាប់ថែទាំសុខភាព SR-០៣២១ទទួលបានការឧបត្ថម្ភ១០០ដុល្លារអាមេរិកសំរាប់ការថែទាំសុខភាព SR-0432ទទួលបានការឧបត្ថម្ភ៨១០ដុល្លារអាមេរិកសំរាប់ការព្យាបាលជម្ងឺនិងធ្វើបុណ្យសពរបស់នាង PP-៣៨៤២ទទួលបានការឧបត្ថម្ភ៤០០ដុល្លារអាមេរិកសំរាប់សំរាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យ និងPP-០៣៦៤បានទទួលការឧបត្ថម្ភសំរាប់សោហ៊ុយធ្វើទៅបើកថ្នាំARV។ |
| **៣.៨.៤ កម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ** | |
| 3.8.4.1 ជួយគាំទ្រការអនុវត្តសកម្មភាពការងារប្រចាំថ្ងៃរបស់ក្រុមអ្នកដឹកនាំ(Team leaders) នៅមណ្ឌលស្តារនីតិសម្បទាទុំឌីអោយមានប្រសិទ្ធិភាព លើសកម្មភាពការងារស្នូលទាំ៤(ដូចបានចែងក្នុងគោលនយោបាយក្រុមអ្នកដឹកនាំ)។ | 3.8.4.1 យើងបានប្រជុំជាមួយក្រុមអ្នកដឹកនាំបានចំនួន៤ដងនៅក្នុងមណ្ឌល។ ការប្រជុំត្រូវបានធ្វើឡើងតាមរយៈការប្រជុំផ្ទាល់និងតាមអនឡាញ គោលបំណងនៃការប្រជុំគឺពង្រឹងសីលធម៌ វិន័យនិងបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌល ដោះស្រាយបញ្ហារបស់យុវនារី-កុមារីដែលមានអារម្មណ៍ធ្លាក់ចុះក្នុងរយៈដាក់ដោយឡែកដោយសារវិបត្តិនៃការរាតត្បាតមេរោគកូវីដ-១៩ ការលួចរបស់គ្នា ផ្អាកការទៅលេងគ្រួសារដោយការរាតត្បាតមេរោគកូវីដ១៩ក្នុងរយៈ២ឆ្នាំ បញ្ហាប្រឈមរបស់ក្រុមអ្នកដឹកនាំក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃរបស់ពួកគាត់ជាមួយសមាជិកក្រុម ដែលមានវ័យចាស់ជាងពួកគាត់ ពីព្រោះពួកគេមិនស្តាប់ពួកគាត់ទេ។ |

| | |
|---|---|
| 3.8.4.2 នឹងជួយយុវនារី-កុមារីរៀបចំបោះឆ្នោតចំនួន២ដង ក្នុងចំណោមយុវនារី-កុមារីផ្ទាល់នៅក្នុងមណ្ឌលទុំឌី ដើម្បីជ្រើសរើសមេក្រុមអ្នកដឹកនាំតាមឆន្ទរបស់ពួកគាត់ចង់បាន ធ្វើជាតំណាងអ្នកនាំសម្លេងនៃតម្រូវរបស់ពួកគាត់នៅមណ្ឌល។ | 3.8.4.2 បានរៀបចំការបោះឆ្នោតចំនួន១ដង នៅខែកុម្ភៈ ឆ្នាំ២០២១ ដោយយុវនារី-កុមារីផ្ទាល់និងមានការជួយគាំទ្រពីសំណាក់សមាជិកអ្នកដឹកនាំរបស់កម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះបានប្រព្រឹត្តិទៅនៅមណ្ឌលស្តារនីតិសម្បទាទុំឌី យុវនារី-កុមារីចំនួន៦នាក់ត្រូវបានជ្រើសរើសជាមេក្រុមដឹកនាំតាមរយៈការបោះឆ្នោតសំរាប់អាណត្តិ៦ខែ។ យើងបានសំរេចកែរប្រែគោលនយោបាយក្រុមអ្នកដឹកនាំពីការបោះឆ្នោត១ឆ្នាំ២ង មក១ឆ្នាំ១ដងវិញ។ |
| 3.8.4.3 ឈរជាសម្លេងអោយអតីតជនរងគ្រោះក្នុងនីតិវិធីដំណើរការជ្រើសរើសអតីអជនរងគ្រោះអោយទទួលប្រាក់ហោប៉ៅឧបត្ថម្ភប្រចាំខែពីនាយករដ្ឋាមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ | 3.8.4.3 ប្រធានកម្មវិធីសែន (SEN) បានធ្វើការយ៉ាងជិតស្និតជាមួយបណ្តាកម្មវិធីពាក់ព័ន្ធក្នុងការជ្រើសរើសយុវនារី-កុមារី ចំនួន១០៣នៃចំណោម១១៩នាក់អោយទទួលបានប្រាក់ហោប៉ៅឧបត្ថម្ភប្រចាំខែពីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះចំនួន៦៦នាក់ជាយុវនារី-កុមារីស្នាក់នៅក្នុងមណ្ឌល ២៥នាក់ជាយុវនារី-កុមារីអប់រំសហគមន៍ និង១២នាក់ទៀតជានិស្សិតអាហារូបករណ៍ ។ យុវនារី-កុមារី១នាក់ទទួលបានប្រាក់ហោប៉ៅឧបត្ថម្ភប្រចាំខែចំនួន១០០,០០០.០០រៀល(២៥ដុល្លារអាមេរិក) ក្នុង១ខែ។ រីឯ១៦នាក់ទៀតយើងបម្រុងទុកសំរាប់ករណីយុវនារី-កុមារីចូលថ្មីជាបន្តបន្ទាប់នៅមណ្ឌលស្តារនីតិសម្បទាទុំឌី។ |
| 3.8.4.4 យើងនឹងធ្វើការជ្រើសរើសជាផ្លូវការយុវនារីចំនួន៥០នាក់ចូលជាសមាជិនសែន (SEN) តាមរយៈការបំពេញទំរង់បែបបទជាសមាជិកសែនផ្លូវការ។ | 3.8.4.4 យុវនារីចំនួន២១នាក់ត្រូវបានកំណត់អត្តសញ្ញណ្ណជ្រើសរើសចូលជាសមាជិកកម្មវិធីសែន ប៉ុន្តែពួកគាត់មិនទាន់បានបំពេញទំរង់បែបបទសមាជិកនៅឡើយទេដោយសារការរាតត្បាតមេរោគកូវីដ-១៩ យើងនឹងតម្រូវអោយពួកគាត់បំពេញតាមនីតិវិធីនៅពេលណាការរាតត្បាតបានប្រសើរឡើង ។ សមាជិក២០នាក់នៅភ្នំពេញ និង១នាក់ទៀតនៅសៀបរាប។ |

| | |
|---|---|
| 3.8.4.5 យើងនឹងរៀបចំការប្រជុំ(អាហារសាមគ្គីថ្ងៃត្រង់)ចំនួន២ដង ជាមួយសមាជិកសែន ដោយរៀបចំប្រជុំនៅរាជធានីភ្នំពេញ១ដង និងនៅខេត្តសៀមរាប១ដង ការប្រជុំនេះធ្វើឡើងក្នុងគោលបំណងចែករំលែកបទពិសោធន៍ បញ្ហាប្រឈម ចែករំលែកព័ត៌មានអំពីបច្ចុប្បន្នភាពការងារសែន និងពង្រឹងទំនាក់ទំនងរវាងសមាជិកនីមួយៗក្នុងក្រុម។ | 3.8.4.5 យើងមិនបានអនុវត្តសកម្មការងារនេះទេ ដោយសារបញ្ហាការផ្ទុះឡើងនូវមេរោគកូវីដ-១៩ ជះឥទ្ធិពលដល់ការធ្វើដំណើរ។ |
| 3.8.4.6 ជាតំណាងអោយអតីតជនរងគ្រោះដោយការចូលរួមយ៉ាងសកម្មក្នុងការប្រជុំនិងការពិភាក្សាផ្ទៃក្នុង ជាមួយបណ្តាបុគ្គលិកកម្មវិធីផ្សេង ៗ នូវកម្មវិធីស្នូលទាំង៤រួមមាន ស្តារនីតិសម្បទា អប់រំនិងហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ លើកកម្ពស់សេដ្ឋកិច្ច និងបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ ក្នុងគោលបំណងនាំមកនូវផលប្រយោជន៍ជូនអតីតជនរងគ្រោះ។ | 3.8.4.6 ប្រធានកម្មវិធីសែនបានចូលរួមប្រជុំផ្ទៃក្នុងប្រចាំសប្តាហ៍និងប្រចាំខែជាច្រើនជាមួយបណ្តាកម្មវិធីពាក់ព័ន្ធ ស្តីពីការគ្រប់គ្រងករណីដែលទាក់ទងនិងយុវនារី-កុមារីនីមួយ ៗ ស្នាក់នៅក្នុងមណ្ឌល និស្សិតអាហារូបករណ៍ហ្វឹក ហ្វឺនជំនាញខាង ក្រៅអប់រំសហគមន៍ និងសមាហរណកម្មដែលត្រូវការស្វែងរកដំណោះស្រាយនិងជំនួយ។ |

## IV. របាយការណ៍ ហិរញ្ញវត្ថុ

ជាទូទៅ យើងធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់យើង ដោយការជួលក្រុមហ៊ុនសវនកម្មឯកជននៅក្នុងរង្វង់ខែកក្កដា ជារៀងរាល់ឆ្នាំ ហើយក្រុមហ៊ុនសវនកម្មត្រូវការពេលវេលាប្រហែល៣-៤ សប្តាហ៍ដើម្បីបញ្ចប់ការធ្វើសវនកម្ម និងផ្តល់របាយការណ៍អោយយើង។ ដើម្បីអោយមានគណនេយ្យភាព និងតម្លាភាព យើងតែងតែធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មរបស់យើងជូនម្ចាស់ជំនួយរបស់យើង និងប្រកាសនៅលើគេហទំព័ររបស់អង្គការអាហ្វេស៊ីប កម្ពុជា។ ប្រសិនបើ លោក លោកស្រី នាងកញ្ញា ត្រូវការមើលរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុរបស់យើងកាលពីឆ្នាំមុន ៗ សូមចូលទៅកាន់គេហទំព័ររបស់យើង afesip.org ។